ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប

## ២០២១-២០២៥

សិក្សាស្រាវជ្រាវ និងសម្របសម្រួលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍
តំបន់បឹងទន្លេសាបប្រកបដោយចីរភាព

ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ខែធ្នូ ឆ្នាំ២០២០

# មាតិកា


**បុព្វកថា** ........ ១

**ខ្លឹមសារសង្ខេប** ........ ៣

**ផ្នែកទី១ សេចក្តីផ្តើម** ........ ៥

១.១- សាវតារ ........ ៥

១.២- អាទិភាពសម្រាប់អាជ្ញាធរទន្លេសាប ........ ៥

១.៣- ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ ........ ៦

ដ្យាក្រាមទី១ ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ ........ ៧

១.៤- អំពីទម្រង់នៃការរៀបចំផែនការយុទ្ធសាស្ត្រ ........ ៨

**ផ្នែកទី២ សមិទ្ធផល និងបញ្ហាប្រឈមផែនការយុទ្ធសាស្ត្រ ២០១៦-២០២០** ........ ៩

២.១- សមិទ្ធផល ........ ៩

២.២- បញ្ហាប្រឈម ........ ១៧

**ផ្នែកទី៣ ផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០២១-២០២៥** ........ ១៩

ដ្យាក្រាមទី២ គំនូសបំព្រួញរចនាសម្ព័ន្ធចក្ខុវិស័យ បេសកកម្ម និងសសរស្តម្ភ ........ ១៩

៣.១- ចក្ខុវិស័យ និងបេសកកម្ម ........ ២០

៣.១.១. ចក្ខុវិស័យ ........ ២០

៣.១.២. បេសកកម្ម ........ ២០

៣.២- គោលដៅយុទ្ធសាស្ត្រ និងគោលបំណង ........ ២០

៣.២.១. គោលដៅយុទ្ធសាស្ត្រ ........ ២០

៣.២.២. គោលបំណង ........ ២០

៣.៣- បាវចនា និងរចនាសម្ព័ន្ធរបស់អាជ្ញាធរទន្លេសាប ........ ២០

៣.៣.១. បាវចនា ........ ២០

៣.៣.២. រចនាសម្ព័ន្ធរបស់អាជ្ញាធរទន្លេសាប ........ ២១

ដ្យាក្រាមទី៣ រចនាសម្ព័ន្ធអាជ្ញាធរទន្លេសាប ........ ២១

៣.៤- ទិសដៅយុទ្ធសាស្ត្រ ........ ២២

៣.៥- សកម្មភាពយុទ្ធសាស្ត្រ ........ ២២

៣.៥.១. ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រជាមូលដ្ឋានក្នុងតំបន់បឹងទន្លេសាប ........ ២២

៣.៥.២. ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា ........ ២៣

៣.៥.៣. លើកកម្ពស់ប្រសិទ្ធភាពនៃការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ........ ២៣

៣.៥.៤. ពង្រឹងការគ្រប់គ្រងអង្គភាព/ស្ថាប័ន និងមូលដ្ឋានចំណេះដឹងលើការសិក្សាស្រាវជ្រាវ ........ ២៤

តារាងម៉ាទ្រិកទី១ សកម្មភាពយុទ្ធសាស្ត្រ ........ ២៥

តារាងម៉ាទ្រិកទី២ ទិសដៅយុទ្ធសាស្ត្រ សូចនាករ និងចំណុចដៅ ........ ២៨

ដ្យាក្រាមទី៤ ផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប ២០២១-២០២៥ ........ ៣២

**ផ្នែកទី៤ យន្តការអនុវត្ត និងប្រភពថវិកា ធនធានហិរញ្ញវត្ថុ** ........ ៣៣

៤.១- យន្តការសម្រាប់អនុវត្ត ........ ៣៣

៤.២- ប្រភពថវិកា និងធនធានហិរញ្ញវត្ថុ ........ ៣៣

តារាងម៉ាទ្រិកទី៣ ការប៉ាន់ប្រមាណថវិកាសម្រាប់គោលដៅយុទ្ធសាស្ត្រ ........ ៣៤

តារាងម៉ាទ្រិកទី៤ ការប៉ាន់ប្រមាណថវិកាសម្រាប់ទិសដៅយុទ្ធសាស្ត្រ ........ ៣៤

**ផ្នែកទី៥ ការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងសេចក្ដីសន្និដ្ឋាន** ........ ៣៧

៥.១- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........ ៣៧

៥.១.១. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការសកម្មភាពប្រចាំឆ្នាំ ........ ៣៧

៥.១.២. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រពាក់កណ្ដាលអាណត្តិ(២ឆ្នាំកន្លះ) ........ ៣៧

៥.១.៣. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ .. ៣៨

៥.២- សេចក្ដីសន្និដ្ឋាន ........ ៣៨

**ឧបសម្ព័ន្ធ** ........ ៤០

ឧបសម្ព័ន្ធទី១ ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ស្ដីពីការបង្កើតអាជ្ញាធរទន្លេសាប ...៤០

ឧបសម្ព័ន្ធទី២ ព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ស្ដីពីការកែសម្រួល មាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/ ៧០៥ ស្ដីពីការបង្កើតអាជ្ញាធរទន្លេសាប ........ ៤៧

ឧបសម្ព័ន្ធទី៣ អនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គលេខាធិការ នៃអាជ្ញាធរទន្លេសាប ........ ៥២

ឧបសម្ព័ន្ធទី៤ ប្រកាសលេខ ០២៥ អ.ទ.ស ស្ដីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ការិយាល័យចំណុះបណ្ដានាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប ..... ៥៧

ឧបសម្ព័ន្ធទី៥ អនុក្រឹត្យលេខ ១៩៧ អនក្រ.បក ស្ដីពីការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧.៤០៦ហិកតាស្ថិតក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប........ ៦៤

# បុព្វកថា

ដើម្បីជានាដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាបប្រកបដោយចីរភាពសម្រាប់រក្សាទុកជាកេរ្តិ៍មរតកដ៏ប្រពៃរបស់មនុស្សជាតិយូរអង្វែង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបង្កើតស្ថាប័នមួយស្ថិតក្រោមការគ្រប់គ្រងនៃ**ទីស្តីការគណៈរដ្ឋមន្ត្រី** និងជាសេនាធិការផ្តល់បន្ថែមជួយដល់រាជរដ្ឋាភិបាល គឺ **អាជ្ញាធរអាងទន្លេសាប** តាមព្រះរាជក្រឹត្យលេខ នស/រកត/០៩០៧/៤១២ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៧។

ដោយពិនិត្យលើស្ថានភាពជាក់ស្តែង រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់ឡើងវិញលើរចនាសម្ព័ន្ធនៃការគ្រប់គ្រង និងតួនាទីភារកិច្ចក៏ដូចជាដែនសមត្ថកិច្ចវិសាលភាពនៃការគ្រប់គ្រងរបស់ **អាជ្ញាធរអាងទន្លេសាប** មកជា **អាជ្ញាធរទន្លេសាប** តាមព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ និងព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ ស្តីពីការបង្កើត **អាជ្ញាធរទន្លេសាប**។

តាមរយៈការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ២០១៦-២០២០កន្លងមកអាជ្ញាធរទន្លេសាបបានទទួលនូវសមិទ្ធផលជាច្រើនតាមការរំពឹងទុក និងបានចូលរួមយ៉ាងសកម្មក្នុងការគាំទ្រដល់ក្របខណ្ឌគោលនយោបាយជាតិសំខាន់ៗដូចជា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ សមិទ្ធផលដែលសម្រេចបានតាមរយៈសកម្មភាពសំខាន់ៗរបស់អាជ្ញាធរទន្លេសាបរួមមានការសិក្សាស្រាវជ្រាវតាមដានលើ៖ (១) ទិដ្ឋភាពទូទៅនៃតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធរួមមាន៖ វិសាលភាពនៃបឹងទន្លេសាប សម្ពាធនៃការអភិវឌ្ឍន៍ កំណើនប្រជាជន វិសមភាពនៃសិទ្ធិទទួលផល និងភាពក្រីក្រ (២) ភាពប្រឈមនៃធនធានទឹក និងបរិស្ថានរួមមាន៖ ការកើនកំដៅនៃភពផែនដី ដែលជាកត្តាចម្បងនៃការប្រែប្រួលអាកាសធាតុ ដែលធ្វើឲ្យមានបម្រែបម្រួលរបបជលសាស្ត្រ ការបំពុលទឹក និងគុណភាពទឹក ការទន្ទ្រានដីព្រៃលិចទឹក និងវាលទំនាបលិចទឹក ផលិតភាពនៃធនធានជលផល និងជីវចម្រុះ និង (៣) ភាពប្រឈមសេដ្ឋកិច្ច-សង្គម ដូចជាការប្រកបរបរទ្រទ្រង់ជីវភាពរស់នៅដោយអាស្រ័យផលលើធនធានជលផល និងស្ថានភាពសេដ្ឋកិច្ច-សង្គមជាដើម។

ជាការពិត សមិទ្ធផលទាំងឡាយដែលអាជ្ញាធរទន្លេសាបសម្រេចបានកន្លងមកនេះ គឺដោយសារមានការរៀបចំផែនការប្រចាំឆ្នាំ និងកម្មវិធីអនុវត្តច្បាស់លាស់ដែលមានរចនាសម្ព័ន្ធការងារត្រឹមត្រូវ និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការអនុវត្តការងារប្រកបដោយវិជ្ជាជីវៈល្អ។

ខ្ញុំមានមោទនភាពក្នុងការបង្ហាញនូវផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាបរយៈពេល៥ឆ្នាំ (២០២១-២០២៥) សម្រាប់នីតិកាលទី៦ ដែលជាដំណើរការរបស់ស្ថាប័នក្នុងការកំណត់ទិសដៅទៅអនាគត។ ផែនការយុទ្ធសាស្ត្រ ២០២១-២០២៥ ជាផែនការមានលក្ខណៈប្រមូលផ្តុំ និងឆ្លុះបញ្ចាំងនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលមធ្យមរបស់អាជ្ញាធរទន្លេសាប រួមចំណែកគាំទ្រទៅនឹងក្របខណ្ឌគោលនយោបាយជាតិ ដូចជាយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ ជាដើម។

កិច្ចការសំខាន់ គឺការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រ និងសម្របសម្រួលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាបប្រកបដោយចីរភាព។

ផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប២០២១-២០២៥ នឹងបង្ហាញអំពីគោលបំណង គោលដៅយុទ្ធសាស្ត្រ ទិសដៅយុទ្ធសាស្ត្រ និងសកម្មភាពយុទ្ធសាស្ត្រ អមដោយលទ្ធផល សូចនាករ ពេលវេលាថវិកា យុទ្ធសាស្ត្រ និងយន្តការអនុវត្ត ការតាមដាន ការត្រួតពិនិត្យ ការវាយតម្លៃ និងការសន្និដ្ឋាន ដែលបែកចេញជា ៥ ផ្នែក គឺផ្នែកទី១ ប្រសិទ្ធភាពនៃការសិក្សាស្រាវជ្រាវតាមដានការអនុវត្តន៍កន្លងមក ព្រមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីធ្វើឲ្យស៊ីចង្វាក់គ្នាជាមួយនឹងផែនការអភិវឌ្ឍជាតិ ព្រមទាំងការប្រែប្រួលនៃប្រព័ន្ធអេកូស៊ីស្តែមរបស់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ និងការប្រែប្រួលអាកាសធាតុ។ ផ្នែកទី២ សមិទ្ធផល និងបញ្ហាប្រឈមលើការអនុវត្តផែនការយុទ្ធសាស្ត្រ២០១៦-២០២០ ដើម្បីជាធាតុចូលក្នុងការរៀបចំផែនការយុទ្ធសាស្ត្របន្តនេះ។ ផ្នែកទី៣ ការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ ២០២១-២០២៥ ដើម្បីបន្តបេសកកម្មពីផែនការយុទ្ធសាស្ត្រ ២០១៥-២០២០ ព្រមទាំងឆ្លើយតបទៅនឹងការអភិវឌ្ឍន៍កាន់តែខ្លាំងក្នុងអំឡុងពេល ២ ទៅ ៣ ឆ្នាំកន្លងមក និងពេលខាងមុខ។ ផ្នែកទី៤ យន្តការសម្រាប់អនុវត្ត ប្រភពថវិកា និងធនធានហិរញ្ញវត្ថុ យោងតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងផែនការ។ ផ្នែកទី៥ យន្តការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងសេចក្តីសន្និដ្ឋាន។

ខ្ញុំសង្ឃឹមថា ផែនការយុទ្ធសាស្ត្រនេះនឹងជួយតម្រង់ទិសការងារដល់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប និងផ្តល់កិច្ចសហការណ៍ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមជាមួយដៃគូអភិវឌ្ឍន៍នានាដែលមានគោលបំណងចូលរួមសហការ និងគាំទ្រដល់អាជ្ញាធរទន្លេសាប ដើម្បីសម្រេចបានជោគជ័យប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ ២០២១-២០២៥។

ជាទីបញ្ចប់ខ្ញុំសូមកោតសសើរដោយស្មោះ ចំពោះឯកឧត្តម លោកជំទាវ អស់លោក-លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទអាជ្ញាធរទន្លេសាប តំណាងពីក្រសួងធនធានទឹក និងឧតុនិយម តំណាងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងស្ថាប័នពាក់ព័ន្ធនានា ដែលបានសហការចូលរួមផ្តល់យោបល់ និងអនុសាសន៍ដើម្បីគាំទ្រដល់ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រនេះប្រកបដោយជោគជ័យ និងសូមជូនពរ ឯកឧត្តម លោកជំទាវ អស់លោក-លោកស្រីទាំងអស់ ទទួលបាននូវពុទ្ធពរទាំង ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអង្គារ ៨ [illegible] ខែ[illegible] ឆ្នាំជូត ទោស័ក ពស២៥៦៤

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ [illegible] ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**និងជា ប្រធានអាជ្ញាធរទន្លេសាប**

[illegible]

**លឹម គានហោ**

# ខ្លឹមសារសង្ខេប

ផែនការយុទ្ធសាស្ត្រ ២០២១-២០២៥ របស់អាជ្ញាធរទន្លេសាបនេះ គឺជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលមធ្យមលើកទី២។ ការរៀបចំផែនការយុទ្ធសាស្ត្រនេះ គឺចាប់ផ្ដើមដោយរៀបចំក្រុមការងារដើម្បីសិក្សាលើឯកសារពាក់ព័ន្ធដូចជា៖ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ ផែនការយុទ្ធសាស្ត្ររបស់ក្រសួងធនធានទឹក និងឧតុនិយម ផែនការយុទ្ធសាស្ត្ររបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ក្របខណ្ឌយុទ្ធសាស្ត្រវិស័យជលផល ផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប ២០១៦-២០២០ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។

ការរៀបចំផែនការយុទ្ធសាស្ត្រនេះ គឺដើម្បីគាំទ្រដល់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ លើមុំទី ៤ (ការអភិវឌ្ឍប្រកបដោយចីរភាព) សំដៅលើការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ប្រកបដោយចីរភាព។ ដើម្បីសម្រេចនូវគោលបំណង គោលនយោបាយនេះ អាជ្ញាធរទន្លេសាប បានកំណត់នូវចក្ខុវិស័យច្បាស់លាស់គឺ " **អាជ្ញាធរទន្លេសាបជាស្ថាប័នថ្នាក់ជាតិមួយក្នុងការសិក្សាស្រាវជ្រាវ និងសម្របសម្រួលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាបប្រកបដោយចីរភាព** "។

ដើម្បីគាំទ្រដល់ចក្ខុវិស័យនេះ បេសកកម្មអាទិភាពចំនួន៣ ត្រូវបានកំណត់មានជាអាទិ៍៖ (១) ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រ និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍប្រកបដោយចីរភាព (២) សម្របសម្រួល និងប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើឲ្យប្រសើរឡើងវិញនូវធនធានធម្មជាតិនៃតំបន់បឹងទន្លេសាប (៣) ពង្រឹងធនធានមនុស្ស មូលដ្ឋានទិន្នន័យ និងទំនាក់ទំនងកិច្ចសហប្រតិបត្តិការ។ ផែនការយុទ្ធសាស្ត្រនេះ គឺបានបន្សុីជាមួយផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងធនធានទឹក និងឧតុនិយម ផងដែរ។

ថវិកាជាផ្នែកមួយដ៏សំខាន់សម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រ ២០២១-២០២៥ នេះឲ្យបានជោគជ័យ ដោយត្រូវពឹងផ្អែកលើប្រភពថវិការបស់រាជរដ្ឋាភិបាល ឬថវិកាកម្មវិធី និងថវិកាពីប្រភពផ្សេងៗតាមរយៈការកៀរគរម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍។ តាមការប៉ាន់ប្រមាណសម្រាប់តម្រូវការចំណាយក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះគឺ ២៦,៧០០ លានរៀល (ម្ភៃប្រាំមួយពាន់ប្រាំពីររយលានរៀលគត់) ក្នុងរយៈពេល៥ឆ្នាំ។ ក្នុងនោះដែរអាជ្ញាធរទន្លេសាប និងដើរតួនាទីសម្របសម្រួលដើម្បីទាក់ទាញ និងកៀរគរប្រភពថវិកាផ្សេងៗក្រៅពីកញ្ចប់ថវិការបស់រាជរដ្ឋាភិបាលផ្តល់ប្រចាំឆ្នាំ ដែលជាទុនបដិភាគ ឬវិភាគទានបន្ថែមបានពីវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយនានាតាមរយៈការសរសេរគម្រោងស្នើសុំ និងការសហការសិក្សាស្រាវជ្រាវផ្សេងៗ។

សមិទ្ធផលរំពឹងទុកនៃផែនការយុទ្ធសាស្ត្រនេះ គឺមានគោលដៅយុទ្ធសាស្ត្រអាទិភាពចំនួន៤ រួមមាន៖ (១) ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រជាមូលដ្ឋានក្នុងតំបន់បឹងទន្លេសាប (២) ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា (៣) លើកកម្ពស់ប្រសិទ្ធភាពនៃការសម្របសម្រួលជាមួយ

ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ និង(៤) ពង្រឹងការគ្រប់គ្រងអង្គភាព/ស្ថាប័ន និងមូលដ្ឋានចំណេះដឹងលើការសិក្សាស្រាវជ្រាវ។

ដើម្បីសម្រេចលទ្ធផលរំពឹងទុកខាងលើនេះ អាជ្ញាធរទន្លេសាប បានកំណត់ទិសដៅយុទ្ធសាស្ត្រចំនួន១០ ទៅតាមសកម្មភាពការងារប្រទាក់ក្រឡាគ្នា រួមមានជាអាទិ៍ៈ

១- ជំរុញប្រសិទ្ធភាព និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវតាមដានលើអេកូស៊ីសស្តែមតំបន់បឹងទន្លេសាប
២- ពង្រឹងប្រសិទ្ធភាពនៃការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍ ព្រមទាំងការតាមដានត្រួតពិនិត្យសកម្មភាពដែលបាន និងកំពុងអនុវត្ត
៣- ពង្រឹងការតាមដានជាសកម្មលើផលប៉ះពាល់លើអេកូស៊ីសស្តែម និងសម្របសម្រួលតាមការប្រែប្រួលអាកាសធាតុតំបន់បឹងទន្លេសាបទាំងលើធនធានធម្មជាតិ ទាំងលើវិស័យសង្គម/សេដ្ឋកិច្ច
៤- ពង្រឹងប្រសិទ្ធភាព និងការរៀបចំគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់អាជ្ញាធរទន្លេសាប
៥- ពង្រឹងកិច្ចសហប្រតិបត្តិការ និងការគ្រប់គ្រងលើការចែករំលែកព័ត៌មានវិទ្យា
៦- ជំរុញប្រសិទ្ធភាពយន្តការសម្របសម្រួល និងប្រឹក្សាយោបល់
៧- លើកកម្ពស់ប្រសិទ្ធភាពកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ
៨- លើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងដំណើការស្ថាប័នប្រកបដោយចីរភាព
៩- អភិវឌ្ឍន៍គោលនយោបាយយុទ្ធសាស្ត្រ និងកសាងផែនទីបង្ហាញផ្លូវសម្រាប់តំបន់បឹងទន្លេសាប
១០-ពង្រឹងសមត្ថភាពមន្ត្រីរាជការលើការសិក្សាស្រាវជ្រាវតាមដានលើប្រធានបទនីមួយៗតាមគោលដៅរបស់អាជ្ញាធរទន្លេសាប។

ការអនុវត្តផែនការយុទ្ធសាស្ត្រ៥ឆ្នាំ(២០២១-២០២៥) របស់អាជ្ញាធរទន្លេសាប គឺជាការងារស្នូលរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដែលនឹងត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះតាមរយៈ ១) ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការសកម្មភាពប្រចាំឆ្នាំ ២) ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការពាក់កណ្ដាលអាណត្តិ (២ឆ្នាំកន្លះ) និង ៣) ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរយៈពេល៥ឆ្នាំ។

អាជ្ញាធរទន្លេសាបសង្ឃឹមថា ស្ថាប័នពាក់ព័ន្ធទាំងឡាយក៏ដូចជាដៃគូអភិវឌ្ឍន៍នានា នឹងសហការអនុវត្ត និងតាមដានការអនុវត្តផែនការនេះឲ្យបានជោគជ័យតាមលទ្ធផលដែលបានគ្រោងទុក។ ហើយក៏រំពឹងផងដែរថា ផែនការយុទ្ធសាស្ត្រនេះនឹងរួមចំណែកគាំទ្រដល់ការសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ សំដៅធ្វើឲ្យកម្ពុជាបានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

# ផ្នែកទី១
# សេចក្តីផ្តើម

## ១.១. សាវតារ

ដើម្បីធានាដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍប្រកបដោយចីរភាព និងសម្រាប់រក្សាទុកជាកេរ្តិ៍មរតកដ៏ប្រពៃរបស់មនុស្សជាតិយូរអង្វែង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបង្កើតស្ថាប័នថ្មីមួយស្ថិតក្រោមការគ្រប់គ្រងនៃ**ទីស្តីការគណៈរដ្ឋមន្ត្រី** និងជាសេនាធិការផ្ទាល់បន្ថែមជួយដល់រាជរដ្ឋាភិបាលគឺ **អាជ្ញាធរអាងទន្លេសាប** តាមព្រះរាជក្រឹត្យលេខ នស/រកត/០៩០៧/៤១២ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៧។ យោងលើការពិនិត្យជាក់ស្តែងរាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់ឡើងវិញលើរចនាសម្ព័ន្ធនៃការគ្រប់គ្រង និងតួនាទីភារកិច្ច ក៏ដូចជាដែនសមត្ថកិច្ចវិសាលភាពនៃការគ្រប់គ្រងរបស់អាជ្ញាធរអាងទន្លេសាប មកជា **អាជ្ញាធរទន្លេសាប** តាមព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ និងព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ ស្តីពីការបង្កើត អាជ្ញាធរទន្លេសាប។

## ១.២. អាទិភាពសម្រាប់អាជ្ញាធរទន្លេសាប

អាជ្ញាធរទន្លេសាប ត្រូវដើរតួនាទីយ៉ាងសំខាន់ ជាពិសេសអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ត្រូវយកចិត្តទុកដាក់ឲ្យបានខ្លាំងក្លាបំផុត ចំពោះការអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ (២០២១-២០២៥) ស្របទៅតាមចំណុចអាទិភាពចម្បងដូចខាងក្រោម៖

- កៀរគរបង្កើនធនធានហិរញ្ញវត្ថុដើម្បីបង្កលទ្ធភាពដល់ការចុះសិក្សាស្រាវជ្រាវជាមូលដ្ឋានឲ្យបានពេញលេញស្របតាមមុខងាររបស់ស្ថាប័ន/អង្គភាពប្រចាំថ្ងៃ
- បន្តពង្រឹងពង្រីកលើការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រ និងសម្របសម្រួលលើការគ្រប់គ្រង អភិរក្សនិងអភិវឌ្ឍលើការចែករំលែក និងផ្សព្វផ្សាយ អំពីដំណើរការអនុវត្តសកម្មភាពបច្ចេកទេសដែលជាមូលដ្ឋានគ្រឹះរួមមាន៖
    - ពង្រឹងពង្រីកការពិគ្រោះយោបល់ ការចែករំលែក និងផ្សព្វផ្សាយពីបច្ចេកទេសនៃការសិក្សាស្រាវជ្រាវ លទ្ធផលរបកគំហើញពាក់ព័ន្ធនឹងសក្តានុពល និងផលប៉ះពាល់ផ្សេងៗនៃតំបន់បឹងទន្លេសាប ជំរុញសកម្មភាពអាជ្ញាធរទន្លេសាប ឲ្យដើរតួនាទីជាអង្គភាពថ្នាក់ជាតិមួយក្នុងការសិក្សាស្រាវជ្រាវ និងសម្របសម្រួលលើការចែករំលែក និងផ្សព្វផ្សាយព័ត៌មានទិន្នន័យដល់ភាគីពាក់ព័ន្ធ
    - រៀបចំ និងផ្សព្វផ្សាយពីរបាយការណ៍ ស្តីពីស្ថានភាពតំបន់បឹងទន្លេសាប
    - រៀបចំ និងផ្សព្វផ្សាយពីគោលនយោបាយសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងតំបន់បឹងទន្លេសាបប្រកបដោយចីរភាព

- រៀបចំ និងផ្សព្វផ្សាយពីផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងតំបន់បឹងទន្លេសាបប្រកបដោយចីរភាព
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធទាំងថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិឲ្យកាន់តែស៊ីជម្រៅ

- ពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ព័ត៌មានវិទ្យាសាស្ត្រតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ជំរុញក្រុមការងារ/ជំនាញផ្នែកបច្ចេកទេស ផ្នែករដ្ឋបាល និងការគ្រប់គ្រងគម្រោងរួមជាមួយមន្ត្រីរាជការបម្រើការងារនៅអាជ្ញាធរទន្លេសាបដែលមានជំនាញពាក់ព័ន្ធផ្សេងៗដើម្បីជួយដល់ដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រឲ្យសម្រេចបានជោគជ័យ
- លើកកម្ពស់ភាពជាដៃគូ រួមទាំងដៃគូបច្ចេកទេស ធនធានមនុស្ស និងហិរញ្ញវត្ថុ។

## ១.៣. ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ

ការរៀបចំផែនការយុទ្ធសាស្ត្រ ២០២១-២០២៥ របស់អាជ្ញាធរទន្លេសាប គឺធ្វើឡើងក្នុងក្របខណ្ឌគោលនយោបាយនៃការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយនិរន្តរភាព ពិសេសការកសាងផែនការនេះគឺសម្រាប់ការគ្រប់គ្រងស្ថាប័នអាជ្ញាធរទន្លេសាប ដែលដើរតួនាទីយ៉ាងសំខាន់ជាសេនាធិការផ្ទាល់ឲ្យរាជរដ្ឋាភិបាលលើរាល់គម្រោងការសិក្សាស្រាវជ្រាវ ត្រួតពិនិត្យ និងផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលក្នុងការរួមចំណែកគាំទ្រយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ដូចគ្នានេះដែរ ការរៀបចំផែនការយុទ្ធសាស្ត្រនេះឡើង គឺស្របតាមគោលការណ៍ណែនាំរបស់ក្រសួងផែនការ និងដើម្បីបង្ហាញជាភស្តុតាងដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីវិភាជន៍ថវិកាប្រចាំឆ្នាំតាមសកម្មភាពការងារ និងសូចនាករជាក់លាក់។ ដំណើរការនៃការរៀបចំនេះ ត្រូវធ្វើឡើងតាមដំណាក់កាលដូចខាងក្រោម៖

**ដំណាក់កាលទី១ ការកសាងសេចក្តីព្រាងបឋម** អគ្គលេខាធិការដ្ឋានបានរៀបចំក្រុមការងារដើម្បីសិក្សានូវឯកសារពាក់ព័ន្ធនានា ដូចជាយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ និងផែនការសកម្មភាពប្រចាំឆ្នាំពាក់ព័ន្ធផ្សេងៗរបស់អង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន។ ក្រោយពីការសិក្សាឯកសារពាក់ព័ន្ធ ក្រុមការងារបានរៀបចំកិច្ចប្រជុំផ្ទៃក្នុងដើម្បីពិនិត្យមើលលើអាទិភាពទាំងឡាយសម្រាប់រៀបចំសេចក្តីព្រាងបឋម និងកិច្ចប្រជុំអគ្គលេខាធិការដ្ឋាន ដែលមានតំណាងនាយកដ្ឋានទាំង ៤ ចូលរួមពិគ្រោះយោបល់ និងផ្តល់ធាតុចូលបន្ថែម។

**ដំណាក់កាលទី២ ការកសាងសេចក្តីព្រាងលើកទី១** សេចក្តីព្រាងបឋមត្រូវបានដាក់ចូលក្នុងការពិគ្រោះយោបល់ក្នុងអគ្គលេខាធិការដ្ឋាន និងបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងបឋមដើម្បីកែសម្រួល និងប្រមូលធាតុចូលបន្ថែម ដោយមានការចូលរួមពី អនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង ទីប្រឹក្សា ជំនួយការ ប្រធាននាយកដ្ឋានក្រោមឱវាទ មន្ត្រីជំនាញពាក់ព័ន្ធ ព្រមទាំងមានការចូលរួមពីតំណាងក្រសួងធនធានទឹក និងឧតុនិយម និងតំណាងគណៈកម្មការជាតិទន្លេមេគង្គកម្ពុជា។

**ដំណាក់កាលទី៣ ការកសាងសេចក្តីព្រាងលើកទី២** អគ្គលេខាធិការដ្ឋានបានប្រជុំពិនិត្យកែសម្រួលខ្លឹមសារបន្ថែមតាមយោបល់ស្នាតើកិច្ចប្រជុំការកសាងសេចក្តីព្រាងលើកទី១ និងធាតុចូលផ្សេងៗទៀតពីសមាជិកនៃអង្គប្រជុំពិសេសនាយកដ្ឋានជំនាញទាំង៤។

**ដំណាក់កាលទី៤ ការពិនិត្យ និងអនុម័តលើសេចក្តីព្រាងចុងក្រោយ** អគ្គលេខាធិការដ្ឋានបានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំ ដែលមានការដឹកនាំដោយតំណាងឯកឧត្តមប្រធាន និងមានការចូលរួមពីអនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង ទីប្រឹក្សា ជំនួយការ ប្រធាននាយកដ្ឋាន ក្រុមការងារបច្ចេកទេសពាក់ព័ន្ធ តំណាងក្រសួងធនធានទឹក និងឧតុនិយម តំណាងគណៈកម្មការជាតិទន្លេមេគង្គកម្ពុជា និងស្ថាប័នពាក់ព័ន្ធមួយចំនួនដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងចុងក្រោយ។ បន្ទាប់ពីរៀបចំកិច្ចប្រជុំចុងក្រោយនេះ អគ្គលេខាធិការដ្ឋានបានរៀបចំសម្អាតផែនការយុទ្ធសាស្ត្រទៅតាមស្មារតីកិច្ចប្រជុំ និងរៀបចំគោរពជូន **ឯកឧត្តមប្រធាន** អាជ្ញាធរទន្លេសាបដើម្បីពិនិត្យ និងសម្រេច ចុះហត្ថលេខាឲ្យប្រើប្រាស់ជាផ្លូវការ។

**ដំណាក់កាលទី៥ ការបោះពុម្ព និងដាក់ឲ្យអនុវត្ត** ក្រោយពីការអនុម័តផែនការយុទ្ធសាស្ត្រនេះ ត្រូវបានបោះពុម្ព និងដាក់ឲ្យអនុវត្ត។ អគ្គលេខាធិកាដ្ឋានរៀបចំផ្សព្វផ្សាយដល់ក្រសួង/ស្ថាប័ន អង្គភាព និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា និងធ្វើការបោះពុម្ពផែនការយុទ្ធសាស្ត្រនេះជាភាសាខ្មែរមួយខាង និងភាសាអង់គ្លេសមួយខាង សម្រាប់ចែកជូនទៅដល់អ្នកពាក់ព័ន្ធ។

ដ្យាក្រាមទី១ បង្ហាញអំពីគំនូសបំព្រួញនៃដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប



## ១.៤. អំពីទម្រង់ នៃការរៀបចំផែនការយុទ្ធសាស្ត្រ

ខ្លឹមសារផែនការយុទ្ធសាស្ត្រនេះត្រូវបានរៀបចំតាមលំដាប់លំដោយដូចជាបុព្វកថា ខ្លឹមសារសង្ខេប និងបែងចែកជា៥ផ្នែក រួមមានជាអាទិ៍៖

១) ផ្នែកទី១ គឺសេចក្តីផ្តើម ដែលបានរំលេចអំពីសាវតារ អាទិភាពសម្រាប់អាជ្ញាធរទន្លេសាប ដំណើរការនៃការរៀបចំ និងទម្រង់នៃផែនការយុទ្ធសាស្ត្រ

២) ផ្នែកទី២ បង្ហាញពីសមិទ្ធផលដែលអាជ្ញាធរទន្លេសាបសម្រេចបានក្នុងផែនការយុទ្ធសាស្ត្រ ២០១៦-២០២០ បញ្ហាប្រឈម និងចំណុចខ្វះខាតមួយចំនួនដែលបានជួបប្រទះ

៣) ផ្នែកទី៣ បង្ហាញពីផែនការយុទ្ធសាស្ត្រ២០២១-២០២៥ ដែលរំលេចចំណុចមួយចំនួនដូចជា ចក្ខុវិស័យ បេសកកម្ម គោលដៅយុទ្ធសាស្ត្រ គោលបំណងទិសដៅយុទ្ធសាស្ត្រ និងសកម្មភាពយុទ្ធសាស្ត្រ

៤) ផ្នែកទី៤ បង្ហាញពីយន្តការសម្រាប់អនុវត្តដែលរំលេចពីអង្គភាពទទួលខុសត្រូវ និងរចនាសម្ព័ន្ធការងាររបស់អាជ្ញាធរទន្លេសាប ផែនការថវិកា និងប្រភពធនធានផ្សេងៗសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រទាំងមូល

៥) ផ្នែកទី៥ គឺជាផ្នែកចុងក្រោយដែលបង្ហាញពីយន្តការនៃការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ដែលនឹងរំលេចពីការត្រួតពិនិត្យ តាមដាន និងវាយតម្លៃប្រចាំឆ្នាំ ពាក់កណ្តាលអាណត្តិ (២ឆ្នាំកន្លះ) និងផែនការទាំងមូលរយៈពេល៥ឆ្នាំ និងសេចក្តីសន្និដ្ឋានជារួមសម្រាប់ផែនការយុទ្ធសាស្ត្រនេះ។ក្រៅពីផ្នែកសំខាន់ទាំង៥ ឯកសារផែនការយុទ្ធសាស្ត្រនេះមានភ្ជាប់ឧបសម្ព័ន្ធចំនួន ៥ ដែលជាឯកសារយោង និងបញ្ជាក់នូវខ្លឹមសារលម្អិតដែលមានការពាក់ព័ន្ធ។

# ផ្នែកទី២

# សមិទ្ធផល និងបញ្ហាប្រឈមការអនុវត្តផែនការយុទ្ធសាស្ត្រ ២០១៦-២០២០

សម្រាប់រយៈពេល៥ឆ្នាំ នៃការអនុវត្តផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០១៦-២០២០ បានទទួលនូវសមិទ្ធផល បញ្ហាប្រឈម និងចំណុចខ្វះខាតមួយចំនួនរួមមាន៖

## ២.១- សមិទ្ធផល

ផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០១៦-២០២០ ជាឯកសារផែនការយុទ្ធសាស្ត្រមួយដ៏សំខាន់សម្រាប់រយៈពេលមធ្យម និងជាផែនទីបង្ហាញផ្លូវដែលបានកំណត់ច្បាស់អំពីបេសកកម្មការងារ និងទិសដៅដើម្បីពង្រឹងប្រសិទ្ធភាពការងារជាមួយគោលបំណងជាលទ្ធផលរំពឹងទុក សូចនាករ និងចង្កោមសកម្មភាពរបស់អាជ្ញាធរទន្លេសាបសម្រាប់រយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ និងឆ្លុះបញ្ចាំងពីការចូលរួមលើកកម្ពស់គោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសំដៅរួមចំណែកដល់ការរក្សាឲ្យបាននូវតុល្យភាពនៃការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

ការកំណត់បេសកកម្មការងាររយៈពេល៥ឆ្នាំ ក្នុងការឈានទៅសម្រេចបាននូវចក្ខុវិស័យ "ធ្វើឲ្យអាជ្ញាធរទន្លេសាបជាស្ថាប័ន/អង្គភាពគំរូមួយ ដែលអាចសម្រេចបានជោគជ័យក្នុងការសម្របសម្រួលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍប្រកបដោយចីរភាពក្នុងតំបន់បឹងទន្លេសាប"។ អាជ្ញាធរទន្លេសាបទទួលបានសមិទ្ធផលដែលកំណត់ទិសដៅជាយុទ្ធសាស្ត្រចំនួន៥ រួមជាមួយចង្កោមសកម្មភាពមានដូចខាងក្រោម ៖

### ទិសដៅទី១ ពង្រឹងគោលនយោបាយ បទប្បញ្ញត្តិ និងក្របខណ្ឌស្ថាប័ន

ឈរលើស្មារតីសម្របសម្រួល ដោយមានកិច្ចសហការជាមួយក្រសួងស្ថាប័នបច្ចេកទេស និងដៃគូពាក់ព័ន្ធក្នុងការយកចិត្តទុកដាក់ចែករំលែកព័ត៌មាន/ទិន្នន័យ ផ្សព្វផ្សាយគោលនយោបាយ និងបទប្បញ្ញត្តិនានារបស់រាជរដ្ឋាភិបាលដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដល់ភាគីពាក់ព័ន្ធទាំងនៅកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋានពាក់ព័ន្ធនៅក្នុងតំបន់បឹងទន្លេសាបរួមជាមួយការផ្សព្វផ្សាយការយល់ដឹងអំពីក្របខណ្ឌច្បាប់ និងគោលនយោបាយសំខាន់ៗដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងធនធានទឹក និងបរិស្ថានធនធានធម្មជាតិក្នុងគោលបំណងសំដៅដល់កិច្ចការពារ និងទប់ស្កាត់ផលប៉ះពាល់ដល់ធនធានធម្មជាតិ និងបរិស្ថាននៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធដូចជា ៖

- ច្បាប់ស្តីពី ការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងអមដោយបទប្បញ្ញត្តិអនុក្រឹត្យពាក់ព័ន្ធសំខាន់ៗមួយចំនួនទៀតក្នុងកិច្ចការពារ និងគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព

រួមមាន៖ នីតិវិធីនៃការបង្កើត ការរំលាយចោល និងការកំណត់តួនាទីភារកិច្ចរបស់សហគមន៍កសិករប្រើប្រាស់ទឹក និងការគ្រប់គ្រងអាងទន្លេ

- ច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- ច្បាប់ស្តីពី ជលផល និងច្បាប់ស្តីពី ព្រៃឈើ
- ច្បាប់ស្តីពី តំបន់ការពារធម្មជាតិ។

ជំរុញការខិតខំប្រឹងប្រែង និងសិក្សាស្វែងយល់ពីខ្លឹមសារនៃច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធនីមួយៗ ដែលមានស្រាប់ដើម្បីធ្វើជាមូលដ្ឋានចំណេះដឹងបន្តពង្រឹងសកម្មភាពការងារស្នូលរបស់អង្គភាព និងរៀបចំចងក្រងឲ្យទៅជាសូចនាករសំខាន់ៗសម្រាប់កសាងឯកសារបច្ចេកទេស និងប្រើប្រាស់ជាជំនួយដល់ការសិក្សាស្វែងយល់ និងស្រាវជ្រាវចងក្រងព័ត៌មាន និងទិន្នន័យបន្ថែម។ បន្តការចែករំលែកផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទដែល បាន និងកំពុងបម្រើការងារតាមជំនាញ រួមជាមួយអ្នកពាក់ព័ន្ធ ទាំងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋានតាមរយៈកិច្ចពិភាក្សា អង្គសិក្ខាសាលា សន្និសីទ វេទិកាផ្សេងៗ និងបណ្តាញចែករំលែកព័ត៌មានគេហទំព័រ ប្រព័ន្ធបណ្តាញ សង្គម ទស្សនាវដ្តី សកម្មភាពការងារ និងគោលនយោបាយការងារ។ល។

ក្នុងស្មារតីយកចិត្តទុកដាក់លើការកំណត់ដែនវិសាលភាព (មាត្រា ២) បើទោះបីមិនទាន់ត្រូវបានបញ្ចប់នៅក្នុងដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រ៥ឆ្នាំលើកទី១ អាជ្ញាធរទន្លេសាបបានខិតខំប្រឹងប្រែងពង្រឹងការយល់ដឹងដោយស្វែងយល់លើឯកសារបច្ចេកទេស និងឯកសារច្បាប់ បទប្បញ្ញត្តិពាក់ព័ន្ធដែលមានស្រាប់ដើម្បីប្រមូលផ្តុំចងក្រងមកធ្វើជាទឡ្ហីករណ៍សម្រាប់ជាធាតុចូលដ៏សំខាន់ ដែលអាចប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំបច្ចុប្បន្នភាពឯកសារបច្ចេកទេសបានច្បាស់លាស់ និងបានចុះសិក្សាប្រមូលនូវរាល់ទិន្នន័យសម្រាប់ធ្វើការពិនិត្យផ្ទៀងផ្ទាត់ឡើងវិញតាមទីតាំងជាក់ស្តែង មុននឹងដាក់ស្នើសុំយោបល់ជូនថ្នាក់ដឹកនាំពិនិត្យ និងធ្វើសេចក្តីសម្រេចចិត្តរៀបចំបទប្បញ្ញត្តិក្នុងការកំណត់ដែនវិសាលភាពតំបន់បឹងទន្លេសាប។

ពង្រឹងការអនុវត្តតួនាទី ភារកិច្ច ដូចបានកំណត់ក្នុងអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ តាមរយៈការចុះធ្វើអធិការកិច្ចជាប្រចាំក្នុងសកម្មភាពចូលរួមការពារដែនព្រៃលិចទឹកជុំវិញតំបន់បឹងទន្លេសាប (តំបន់៣) នៅតាមបណ្តាស្រុក ឃុំ និងភូមិពាក់ព័ន្ធជាប់តំបន់ព្រៃលិចទឹក ដែលស្ថិតនៅក្នុងដែនដីរដ្ឋបាលនៃខេត្តទាំង៦នៅជុំវិញតំបន់បឹងទន្លេសាប។ ក្នុងនោះក៏បានចុះផ្ទៀងផ្ទាត់រាល់និយាមកាទាំង៨០២ បង្គោល និងស្វែងយល់ស្រង់ព័ត៌មានទិន្នន័យបន្ថែម អំពីការបាត់បង់ព្រៃលិចទឹក និងការបាត់បង់បង្គោលព្រំប្រទល់ដែលបណ្តាលមកពីសកម្មភាពមនុស្ស និងបង្កមកពីបាតុភូតធម្មជាតិ។ តាមលទ្ធផលនៃការចុះសិក្សាជាក់ស្តែងបានបង្ហាញឲ្យឃើញថា ព្រៃលិចទឹកនៅជុំវិញតំបន់បឹងទន្លេសាបត្រូវបានទទួលរងនូវការទន្ទ្រានយ៉ាងធ្ងន់ធ្ងរ ហើយត្រូវបានបាត់បង់កើនពីមួយឆ្នាំទៅមួយឆ្នាំ។ ជាមួយនឹងការបាត់បង់ និងការកាប់ទន្ទ្រានព្រៃលិចទឹក អាជ្ញាធរទន្លេសាប បានចូលរួមលើកកម្ពស់នូវកិច្ចការការពារថែរក្សាព្រៃលិចទឹក តាមរយៈការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ព្រៃលិចទឹកវិធានការការពារព្រៃលិចទឹក ការដាំឡើងវិញ

និងការបណ្ដុះកូនព្រៃលិចទឹកជាមួយសហគមន៍មូលដ្ឋាន នៅតាមបណ្ដាតំបន់ពាក់ព័ន្ធនៃខេត្តជុំវិញតំបន់បឹងទន្លេសាប។

ដើម្បីសម្រេចបានជោគជ័យនូវទិសដៅយុទ្ធសាស្ត្រទី១ ខាងលើនេះ អាជ្ញាធរទន្លេសាប បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ការងាររបស់អង្គភាពឲ្យមានប្រសិទ្ធភាព និងសាមគ្គីភាពផ្ទៃក្នុងរឹងមាំ ស្របតាមគោលការណ៍ណែនាំបន្ថែមពីថ្នាក់ដឹកនាំ រួមជាមួយការអនុវត្តសកម្មភាពប្រចាំថ្ងៃ និងការចែករំលែក ផ្សព្វផ្សាយនូវព័ត៌មាន របាយការណ៍ពាក់ព័ន្ធជាឯកសារទន់ និងរឹង (Hard and Soft) ដែលបានមកពីលទ្ធផលនៃកិច្ចប្រជុំពិភាក្សា ការប្រឹក្សាយោបល់ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីទទួលយកមកពិនិត្យនូវចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈមសម្រាប់កែលម្អ និងដោះស្រាយបន្តក្នុងដំណើរការការងារអង្គភាពសំដៅឆ្ពោះទៅរកភាពជោគជ័យប្រកបដោយសុខដុមនីយកម្ម។

### ទិសដៅទី២ ពង្រឹងការយល់ដឹងជាមូលដ្ឋាន អំពីការគ្រប់គ្រងតំបន់បឹងទន្លេសាប

ចាប់តាំងពីការបង្កើតអាជ្ញាធរទន្លេសាប សកម្មភាពនៃការប្រមូលចងក្រង និងវិភាគព័ត៌មានទិន្នន័យដែលបានមកពីការចុះសិក្សាស្រាវជ្រាវជាក់ស្ដែងជាច្រើន ត្រូវបានកំណត់ជាសកម្មភាពយុទ្ធសាស្ត្រអាទិភាពនៅក្នុងដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពប្រចាំឆ្នាំរបស់អង្គភាពដើម្បីពង្រឹងពង្រីកដល់ការយល់ដឹងអំពីការគ្រប់គ្រងតំបន់បឹងទន្លេសាប។

ជាមួយនឹងសកម្មភាពនៃការពង្រឹងការយល់ដឹងជាមូលដ្ឋាន អាជ្ញាធរទន្លេសាប បានយកចិត្តទុកដាក់ក្នុងការវិភាគចងក្រងនូវរាល់ព័ត៌មានទិន្នន័យពាក់ព័ន្ធ រួមមាន៖(ក). **ស្ថានភាពសេដ្ឋកិច្ចសង្គម និងការគ្រប់គ្រងធនធានធម្មជាតិ** ដែលជាព័ត៌មានទិន្នន័យពាក់ព័ន្ធជាមួយនឹងស្ថានភាពសង្គម និងចំណេះដឹងលើការប្រើប្រាស់ជាមួយដំណើរការគ្រប់គ្រង អភិបាលកិច្ច ប្រសិទ្ធភាពការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តលើការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន។ (ខ). **ប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានធនធានធម្មជាតិ** ជាការសិក្សាពាក់ព័ន្ធជាមួយស្ថានភាពរបបជលសាស្ត្រ ធនធានទឹក (គុណភាព និងបរិមាណ) តំបន់ដីសើមកាកសំណល់ សក្ដានុពលទេសចរតំបន់បឹងទន្លេសាប និងជីវចម្រុះធនធានធម្មជាតិក្នុងតំបន់បឹងទន្លេសាប ដូចជា៖ ព្រៃលិចទឹក វារីសត្វ សប្បិសត្វ ត្រី រួមទាំងការធ្វើចរាចរត្រី។ (គ). **អាជីវកម្មជលផល និងធនធានរ៉ែក្នុងតំបន់បឹងទន្លេសាប** ជាការសិក្សាពាក់ព័ន្ធទៅនឹងការប្រើប្រាស់ឧបករណ៍នេសាទ ផលនេសាទជាលក្ខណៈគ្រួសារ និងលក្ខណៈអាជីវកម្មធំៗដែលស្ថិតតាមស្ទឹង វាលស្រែ អាងទឹក ប្រព័ន្ធធារាសាស្ត្រ ការសិក្សាផលចាប់តាមឡូត៍ដាយ និងការកែច្នៃផលនេសាទក្នុងតំបន់ជុំវិញបឹងទន្លេសាប រួមជាមួយការធ្វើអាជីវកម្មរ៉ែ។ (ឃ). **ការធ្វើកសិកម្ម ការប្រើប្រាស់ដី និងថ្នាំគីមី** ជាការសិក្សាស្រាវជ្រាវអំពីស្ថានភាពផលិតកម្មកសិកម្ម ការប្រើប្រាស់ដី និងថ្នាំគីមីកសិកម្មរបស់ប្រជាកសិករស្ថិតក្នុងតំបន់១ និងតំបន់២ ក្រោមផ្លូវជាតិលេខ៥ និងលេខ៦ ជុំវិញតំបន់បឹងទន្លេសាប។

លទ្ធផលនៃការចុះសិក្សាស្រាវជ្រាវជាក់ស្ដែង និងការធ្វើបច្ចុប្បន្នភាពព័ត៌មានទិន្នន័យដែលមានស្រាប់បានមកពីប្រភពពាក់ព័ន្ធនានា បានឆ្លុះបញ្ចាំងឲ្យឃើញពីរបកគំហើញក្នុងការប្រែប្រួលបរិយាកាសនៃស្ថាន

ភាពសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ បរិស្ថាន និងដំណើរការនៃការគ្រប់គ្រងពីអ្នកពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោលមកលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធរួមមាន ៖ ធនធានជលផល របបជលសាស្ត្រ ធនធានទឹក ជីវសាស្ត្រចម្រុះ ការទ្រទ្រង់ជីវភាពរស់នៅ ការប្រើប្រាស់ដីធ្លី ការធ្វើអាជីវកម្ម កសិកម្ម ព្រៃលិចទឹកជុំវិញតំបន់បឹងទន្លេសាប ។ល។ ជារួមតាមការសិក្សា និងវិភាគបង្ហាញឲ្យឃើញពីភាពថយចុះ និងការគំរាមកំហែងឥតឈប់ឈរគួរឲ្យព្រួយបារម្ភលើធនធានដ៏កម្រក្នុងតំបន់បឹងទន្លេសាបនាពេលបច្ចុប្បន្ន និងពេលអនាគត ចំពោះសកម្មភាពអនាធិបតេយ្យដោយការ ធ្វើអាជីវកម្មហួសកម្រិតក្នុងការទាញយកអត្ថប្រយោជន៍ធនធានធម្មជាតិពីបឹងទន្លេសាប និងការទទួលរងនូវផលប៉ះពាល់ពីការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធតំបន់មេគង្គខាងលើ តំបន់ជុំវិញបឹងទន្លេសាប និងលើផ្ទៃបឹងទន្លេសាប។

បញ្ហាការគ្រប់គ្រងធនធានធម្មជាតិជាប់ទាក់ទងគ្នាទៅវិញទៅមក ហើយការប្រឈមមុខដាក់គ្នាតែងតែកើតមានឡើងជារឿយៗរវាងក្រុមដែលមានលទ្ធភាពប្រើប្រាស់ធនធានទីទៃពីគ្នា កម្រិតជំនាញក្រសួងស្ថាប័នខុសៗគ្នា និងកម្រិតចំណូលក៏មានភាពខុសពីគ្នាផងដែរ។ ជម្លោះនៅក្នុងតំបន់បឹងទន្លេសាបអាចត្រូវបានមហាជនមើលឃើញពីភាពមិនចុះសម្រុងគ្នារវាងទស្សនៈទូទៅផ្សេងៗគ្នា ដែលលើកឡើងដោយភាគីជម្លោះទាំងអស់នោះនៅក្នុងតំបន់បឹងទន្លេសាប។

ការប្រើប្រាស់ដី ព្រៃលិចទឹក នេសាទខុសច្បាប់ គឺជាឫសគល់នៃជម្លោះជាច្រើនលើធនធានធម្មជាតិនៅក្នុងតំបន់បឹងទន្លេសាប។ ការរុកពានដីនៅក្នុងឋបនីយជីវមណ្ឌលបឹងទន្លេសាប បានធ្វើឲ្យដែនព្រៃលិចទឹកថយចុះដែលបណ្តាលមកពីការកែប្រែដីសម្រាប់ធ្វើកសិកម្ម។ ព្រៃលិចទឹកបម្រើឲ្យមុខងារប្រព័ន្ធអេកូឡូស៊ីមួយចំនួនដោយការពារច្រាំងទន្លេពីសំណឹកដោយសារទឹករលក ផ្តល់ទីជម្រកសម្រាប់មច្ឆជាតិ សត្វស្លាប និងសត្វដែលរស់នៅក្នុងព្រៃលិចទឹកជាច្រើនផ្សេងទៀត ជាមួយគ្នានឹងការផ្តល់នូវសេចក្តីត្រូវការចាំបាច់សម្រាប់មនុស្សលោកទូទៅជាពិសេសសម្រាប់ប្រជាពលរដ្ឋដែលរស់នៅផ្ទាល់ក្នុងបឹងទន្លេសាប និងជុំវិញតំបន់បឹងទន្លេសាប។

ការធ្វើអាជីវកម្មហួសកម្រិត ដែលកើតមានឡើងពីបទល្មើសនេសាទ និងការនេសាទខុសច្បាប់ទៅលើធនធានធម្មជាតិនៅក្នុងបឹងទន្លេសាប គឺនៅតែកើតមានឡើងគំរាមកំហែងលើជីវចម្រុះ ត្រី សត្វល្មូន ធ្វើឲ្យមានការថយចុះជាលំដាប់នៃប្រភេទ បរិមាណ និងទំហំនៃធនធានធម្មជាតិសំខាន់ៗដែលចាប់បាន។ សម្ពាធនៃការនេសាទខុសច្បាប់នៅតែកើតមានឡើងមិនចេះឈប់ឈរ ទោះបីរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលុបចោលឡូត៍នេសាទជុំវិញតំបន់បឹងទន្លេសាប ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងជាកន្លែងអភិរក្សជលផលក្នុងគោលបំណងតែមួយគត់ គឺធ្វើឲ្យសម្បត្តិធនធានធម្មជាតិមួយក្នុងចំណោមសម្បត្តិធម្មជាតិសំខាន់ៗបំផុតជាច្រើនទៀតសម្រាប់សេដ្ឋកិច្ចកម្ពុជា ហើយវាសំខាន់យ៉ាងខ្លាំងសម្រាប់ឋបនីយជីវមណ្ឌលបឹងទន្លេសាបក៏ដោយ។

### ទិសដៅទី៣ សម្របសម្រួល កសាងផែនការ និងការគ្រប់គ្រង

ការបន្តពង្រឹងពង្រីកតួនាទីភារកិច្ចបេសកកម្មស្នូល និងប្រសិទ្ធភាពការងារអំឡុងពេលនៃដំណើរការផែនការយុទ្ធសាស្ត្រ ២០១៦-២០២០ អាជ្ញាធរទន្លេសាប បានចូលរួមសម្របសម្រួលនូវការអនុវត្តការងារជាមួយបណ្តាក្រសួង/ស្ថាប័នជំនាញ និងគម្រោងភាពជាដៃគូតាមរយៈការដាក់ចេញនូវផែនការសកម្មភាពការងារប្រចាំឆ្នាំ ដោយមានការយកចិត្តទុកដាក់គាំទ្រដល់កិច្ចការងារ និងអភិវឌ្ឍន៍បរិស្ថានធនធានធម្មជាតិ និងលក្ខខណ្ឌសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងនោះក៏ចូលរួមផ្តួចផ្តើមគំនិតក្នុងការចែករំលែកការយល់ដឹង បទពិសោធន៍ និងផ្សព្វផ្សាយពីលទ្ធផលរបកគំហើញដែលបានពីការសិក្សាស្រាវជ្រាវ ស្វែងយល់ នឹងប្រមូលចងក្រងធ្វើបច្ចុប្បន្នភាពរាល់ព័ត៌មានទិន្នន័យទៅតាមស្ថានភាពទីតាំងជាក់ស្តែង ដែលបាន និងកំពុងកើតឡើងក្នុងពេលបច្ចុប្បន្ន និងពេលអនាគតទៅលើការគ្រប់គ្រងធនធានជីកម្រនៅតំបន់បឹងទន្លេសាប ជាពិសេសសម្របសម្រួលលើកកម្ពស់ដល់ការយល់ដឹងអំពីការចូលរួមផ្នែកច្បាប់ បទប្បញ្ញត្តិពាក់ព័ន្ធនៃដំណើរការគ្រប់គ្រងធនធានទឹក និងការគ្រប់គ្រងអាងទន្លេដែលរាជរដ្ឋាភិបាលកម្ពុជាបានកំណត់នៅក្នុងច្បាប់ ស្តីពី ការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានដាក់ចេញចាប់តាំងពីឆ្នាំ២០០៧ និងបានចែករំលែកផ្សព្វផ្សាយយល់ដឹងអំពីព័ត៌មានទិន្នន័យផ្សារភ្ជាប់ឯកសារបទដ្ឋានគតិយុត្តនៃដំណើរការអភិវឌ្ឍ និងកិច្ចការពារបរិស្ថាន ធនធានធម្មជាតិប្រកបដោយចីរភាពនៅតំបន់បឹងទន្លេសាប ដែលក្រុមមន្ត្រីជំនាញពាក់ព័ន្ធនៃនាយកដ្ឋានជំនាញទាំង៤ ក្រោមឱវាទបាន និងកំពុងប្រមែប្រមូលចងក្រងទុកធ្វើជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវជាបន្តបន្ទាប់។

ផ្សារភ្ជាប់កិច្ចការសម្របសម្រួលនេះផងដែរ ក៏បានធ្វើការពង្រឹងនូវយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើរាល់ព័ត៌មាន/ទិន្នន័យគម្រោងដែល បាន និងកំពុងអនុវត្តន៍ និងមានផែនការអនុវត្តដែលក្នុងនោះមានគម្រោងគាំទ្រថវិកាដោយរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលតាមរយៈគម្រោងខ្នាតតូចៗតាមសហគមន៍មូលដ្ឋានជុំវិញតំបន់បឹងទន្លេសាបដូចជា៖ ការទាញចេញពីប្រភពក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍ និងសប្បុរសជនផ្សេងៗ ដោយបានធ្វើការពិនិត្យលើឯកសារផែនការគម្រោងមុននឹងចាប់ផ្តើមដែលបានឆ្លុះបញ្ចាំងពីការចូលរួមលើកកម្ពស់ដល់កិច្ចការពារបរិស្ថានធនធានធម្មជាតិ និងកម្រិតជីវភាពរស់នៅរបស់ប្រជាជននៅតំបន់បឹងទន្លេសាប។ ការធ្វើបច្ចុប្បន្នភាពចំនួនគម្រោងមកដល់ចុងឆ្នាំ ២០២០ នេះ សរុបប្រមាណ ១៨៦៥ គម្រោង ក្នុងនោះគម្រោងបានបញ្ចប់ ចំនួន ១២០០ និងកំពុងអនុវត្តន៍ចំនួន ៦៦៥ ជាមួយនីតិវិធីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគម្រោងដែលកំពុងអនុវត្តន៍ និងគ្រោងអនុវត្តបន្តទៀត។ មន្ត្រីជំនាញក្រោមឱវាទអាជ្ញាធរទន្លេសាបបាន និងកំពុងខិតខំប្រឹងប្រែងសម្របសម្រួលប្រាស្រ័យទាក់ទង និងស្នើសុំកិច្ចសហការជាមួយបណ្តាក្រសួង/ស្ថាប័ន និងដៃគូនានាដែលជាភាគីដឹកនាំគម្រោងផ្ទាល់ដើម្បីរៀបចំឲ្យមានយន្តការ នីតិវិធី/វិធីសាស្ត្រ រួមក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរាល់គម្រោងនៅតំបន់បឹងទន្លេសាបក្នុងគោលបំណង បញ្ចៀស នូវការត្រួតជាន់គ្នាក្នុងការអនុវត្ត និងប្រសិទ្ធភាពបន្ទាប់ពីគម្រោងបញ្ចប់។ ដោយកម្រិតការយល់ដឹងរបស់

មន្ត្រីដែលទទួលខុសត្រូវនៅមានកម្រិតក្នុងជំនាញតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី/គម្រោង អាជ្ញាធរទន្លេសាបក៏ជំរុញឲ្យមានការយកចិត្តទុកដាក់ដល់ការពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេស ក្នុងនោះបានជំរុញឲ្យមានកម្មវិធីបណ្តុះបណ្តាលជំនាញតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីគម្រោងប្រចាំឆ្នាំដល់មន្ត្រីរាជការពាក់ព័ន្ធបន្ថែមទៀត។

តាមរយៈលទ្ធផលនៃការចុះអនុវត្តសកម្មភាពការងារសិក្សាស្រាវជ្រាវកន្លងមក អាជ្ញាធរទន្លេសាបបាន និងកំពុងប្រឹងប្រែងធ្វើការវិភាគដោយយកចិត្តទុកដាក់ជាមួយការរៀបចំបញ្ចូលនូវរបាយការណ៍បច្ចេកទេសអំពីលទ្ធផលស្រាវជ្រាវទៅតាមគម្រោងសកម្មភាពនីមួយៗ។ តាមរយៈក្រុមការងារបច្ចេកទេសនីមួយៗដែលដឹកនាំដោយ ឯកឧត្តមអគ្គលេខាធិការត្រូវបានបង្កើតឡើងជាសេនាធិការឲ្យដល់ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមូលផ្តុំរាល់របាយការណ៍ពាក់ព័ន្ធសកម្មភាពស្រាវជ្រាវដើម្បីចងក្រងឲ្យទៅជាកម្រងរបាយការណ៍បច្ចេកទេសគ្រប់សកម្មភាពស្រាវជ្រាវ និងវិភាគឯកសារបច្ចេកទេសដាច់ដោយឡែកពីស្ថានភាពសេដ្ឋកិច្ចសង្គម បរិស្ថាន ធនធានធម្មជាតិ និងការគ្រប់គ្រងតំបន់បឹងទន្លេសាបសម្រាប់ជាមូលដ្ឋានរៀបចំនូវក្របខណ្ឌគោលនយោបាយយុទ្ធសាស្ត្រ ផែនការ និងគម្រោងសកម្មភាព/កម្មវិធីក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាបប្រកបដោយចីរភាព។ ជាក់ស្តែងការដាក់ឲ្យប្រើប្រាស់ និងស្វែងយល់នូវរាល់ឯកសារកម្រងរបាយការណ៍បច្ចេកទេសសិក្សាស្រាវជ្រាវអំពីស្ថានភាពសេដ្ឋកិច្ចសង្គម បរិស្ថាន ធនធានធម្មជាតិ និងការគ្រប់គ្រងតំបន់បឹងទន្លេសាប រួមជាមួយទស្សនាវដ្តី សកម្មភាពការងាររបស់អាជ្ញាធរទន្លេសាប និងកម្រងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិ។

### ទិសដៅទី៤ ការទំនាក់ទំនង និងការកសាងសមត្ថភាពភាគីពាក់ព័ន្ធ

ការពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការ និងផ្សព្វផ្សាយឲ្យបានយល់ដឹងពីសារៈសំខាន់មុខងាររបស់តំបន់បឹងទន្លេសាប ជាពិសេសការបញ្ជ្រាបរាល់ព័ត៌មានឲ្យបានទូលំទូលាយដល់អ្នកពាក់ព័ន្ធអំពីសកម្មភាពការងារ និងវឌ្ឍនភាពការងាររបស់អាជ្ញាធរទន្លេសាប ក្នុងស្មារតីទទួលខុសត្រូវចូលរួមលើកកម្ពស់ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់កិច្ចការពារបរិស្ថានធនធានធម្មជាតិ តំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ។ ជាក់ស្តែងមន្ត្រីក្រោមឱវាទអាជ្ញាធរទន្លេសាបបានខិតខំប្រឹងប្រែងយ៉ាងសកម្មដោយប្រើប្រាស់រាល់ចំណេះដឹង បទពិសោធន៍ និងការយល់ដឹងចេញពីលទ្ធផលនៃការចុះសិក្សាស្រាវជ្រាវតាមទីតាំងផ្ទាល់ធ្វើជាមូលដ្ឋានក្នុងការទំនាក់ទំនង និងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធដែលជាក្រុមគោលដៅក្នុងការបង្កើតជាបណ្តាញដៃគូសន្ទនាការងារក្នុងអង្គប្រជុំ សិក្ខាសាលា វេទិកានានា ទាំងកម្រិតថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។

ការកសាងអភិវឌ្ឍសមត្ថភាពអ្នកពាក់ព័ន្ធ បើទោះជាអាជ្ញាធរទន្លេសាបមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ទាំងថវិកា និងធនធានមនុស្សប្រកបដោយសមត្ថភាពក្នុងការចែករំលែក និងធ្វើការផ្លាស់ប្តូរចំណេះដឹង បទពិសោធន៍ តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាល ឬទស្សនកិច្ចសិក្សាស្វែងយល់ការងារទៅ

វិញទៅមកតាមតំបន់ ឬទីតាំងដាក់ស្តែងឲ្យបានទូលំទូលាយជាមួយបណ្តាភាគីពាក់ព័ន្ធក៏ដោយ ក៏អាជ្ញាធរទន្លេសាប នៅតែបន្តការយកចិត្តទុកដាក់ចំពោះបញ្ហាកង្វះខាតនេះជាអាទិភាពនៅក្នុងផែនការសកម្មភាពជាប្រចាំដើម្បីកៀរគរជំនួយ និងបង្កើនសមត្ថភាពធនធានមនុស្ស។ ពាក់ព័ន្ធបញ្ហាកសាងសមត្ថភាពនេះដែរអាជ្ញាធរទន្លេសាប បាន និងកំពុងតែពង្រឹងពង្រីកចំណេះដឹងដល់មន្ត្រីរាជការរបស់ខ្លួនតាមរយៈវគ្គកសាងសមត្ថភាពជាច្រើនដោយអនុលោមតាមផែនការសកម្មភាពប្រចាំឆ្នាំ និងផ្សារភ្ជាប់ជាមួយលទ្ធផលរបកគំហើញនៃការចុះដាក់ស្តែង។ ក្នុងនោះក៏បានប្រឹងប្រែងយកចិត្តទុកដាក់ដោយប្រើប្រាស់នូវសកម្មភាពការងាររួមជាមួយសូចនាករសំខាន់ៗមួយចំនួនដើម្បីចែករំលែកផ្សព្វផ្សាយការយល់ដឹងជាសាធារណៈរាល់ធាតុសំខាន់ៗនៃដំណើរការគ្រប់គ្រងបរិស្ថានធនធានធម្មជាតិនៅតំបន់បឹងទន្លេសាប វឌ្ឍនភាពការងារ និងសកម្មភាពការងារអង្គភាពទាំងក្នុងកម្រិតជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងថ្នាក់តំបន់ក្នុងកិច្ចប្រជុំសិក្ខាសាលា រួមជាមួយការចែករំលែកតាមបណ្តាញសង្គម និងគេហទំព័ររបស់អាជ្ញាធរទន្លេសាប។ល។

## ទិសដៅទី៥ ការប្រតិបត្តិរបស់អាជ្ញាធរទន្លេសាបប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព

ការពង្រឹងសមត្ថភាពការងារ និងតួនាទីភារកិច្ចអាជ្ញាធរទន្លេសាបដូចបានកំណត់ក្នុងព្រះរាជក្រឹត្យ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ជាពិសេសការដាក់ចេញនូវរាល់គោលនយោបាយរបស់រាជរដ្ឋាភិបាលចំពោះការចូលរួមគិតគូរឲ្យបានស៊ីជម្រៅលើតុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិប្រកបដោយចីរភាព។ តាមរយៈនៃការដាក់ចេញនូវទិសដៅ និងសកម្មភាពក្នុងផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប និងជំរុញប្រសិទ្ធភាពការអនុវត្តដោយប្រើប្រាស់សូចនាករសំខាន់ៗ និងយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃទៅលើប្រសិទ្ធភាពការងារ លទ្ធផលនៃការប្រតិបត្តិការងារប្រចាំឆ្នាំ ដោយជំរុញការអនុវត្តសកម្មភាពដែលបានអនុម័តដាក់បញ្ចូលក្នុងផែនការសកម្មភាពប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ក្នុងនោះក៏បានកំណត់ឲ្យមានរបាយការណ៍ជាប្រចាំតាមការចុះអនុវត្តតាមសកម្មភាពនីមួយៗក្នុងផែនការសកម្មភាពការងារដូចជា៖ របាយការណ៍ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ និងរបាយការណ៍តាមដានការអនុវត្តផែនការសកម្មភាពពាក់កណ្តាលអាណត្តិដើម្បីពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាព និងធ្វើបច្ចុប្បន្នភាព ដើម្បីពង្រឹងការអនុវត្តន៍ផែនការសកម្មភាពការងារប្រចាំឆ្នាំឲ្យកាន់តែមានប្រសិទ្ធភាព។

ការពង្រឹងប្រសិទ្ធភាពការងារដើម្បីឈានទៅសម្រេចទិសដៅយុទ្ធសាស្ត្រតាមការរំពឹងទុក នៅក្នុងក្របខណ្ឌផែនការយុទ្ធសាស្ត្រ ២០១៦-២០២០ អាជ្ញាធរទន្លេសាបតែងតែប្រើប្រាស់បទពិសោធន៍អនុវត្តការងារជាប្រចាំក្នុងការពិនិត្យទៅលើចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈមនានា ដែលបាន និងកំពុងកើតមានឡើងតាមសកម្មភាព វឌ្ឍនភាពការងារ ការប្រជុំពិភាក្សាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីកែតម្រូវសកម្មភាពឲ្យមានសង្គតិភាពជាមួយសូចនាករ និងទិសដៅយុទ្ធសាស្ត្រ។ ជាក់ស្តែងអាជ្ញាធរទន្លេសាប បាន និងកំពុងប្រមូលផ្តុំការប្រឹក្សាយោបល់ និងពិនិត្យលើឯកសាររបាយការណ៍លទ្ធផល

ការងារសកម្មភាពពាក់ព័ន្ធនៅក្នុងគម្រោងសកម្មភាពការងារផែនការប្រចាំឆ្នាំនីមួយៗ ដើម្បីធ្វើបច្ចុប្បន្នភាព រៀបចំតារាងម៉ាទ្រិកសកម្មភាពការងារឈានទៅដល់ការរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ ដើម្បីបន្ត នៅក្នុងឆ្នាំបន្តបន្ទាប់ដែលជាតួនាទី ភារកិច្ច និងការទទួលខុសត្រូវផ្ទាល់របស់អគ្គលេខាធិការដ្ឋានចំពោះ មុខថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប។

ក្នុងការដាក់ចេញនូវទស្សនវិស័យ ទិសដៅយុទ្ធសាស្ត្រ និងកម្មវិធី/គម្រោងសកម្មភាពការងារ ប្រទាក់ក្រឡាគ្នារបស់អង្គភាព អាជ្ញាធរទន្លេសាប ក៏បានប្រើប្រាស់ជាមូលដ្ឋានពង្រឹងពង្រីកបណ្តាញ ទំនាក់ទំនងជាពិសេសការកៀរគរថវិកា និងជំនួយបច្ចេកទេសទាំងផ្នែករដ្ឋាភិបាលកម្ពុជា និងដៃគូភាគី ពាក់ព័ន្ធដោយបានឆ្លុះបញ្ចាំងតាមរយៈការចចារ កិច្ចប្រជុំ ការពិភាក្សា សិក្ខាសាលាចែករំលែកការយល់ដឹង បទពិសោធន៍ក្នុងគោលដៅពង្រីកឥទ្ធិពល និងពង្រឹងប្រសិទ្ធភាពការងារអង្គភាពប្រកបដោយចីរភាព។ បច្ចុប្បន្នក្រសួង/ស្ថាប័នទាំងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងដៃគូអភិវឌ្ឍន៍នានា បាន និងកំពុងមានការចាប់អារម្មណ៍ និងយកចិត្តទុកដាក់យ៉ាងខ្លាំងជាមួយសកម្មភាពការងារ លទ្ធផល របកគំហើញនៃការសិក្សាស្រាវជ្រាវ និងវឌ្ឍនភាពការងាររបស់អាជ្ញាធរទន្លេសាប ដែលមានជាបន្តបន្ទាប់ ក្នុងការយកទៅពិចារណាដើម្បីពិនិត្យលទ្ធភាពគាំទ្រដល់ដំណើរការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹង ទន្លេសាប។ អាជ្ញាធរទន្លេសាប បាន និងកំពុងផ្សារភ្ជាប់ជាមួយបណ្តាញអង្គការអាងទន្លេតាមរយៈគម្រោង កិច្ចសហប្រតិបត្តិការរួមទាំងទស្សនកិច្ចសិក្សាផ្លាស់ប្តូរក្នុងវេទិកា និងសន្និសីទក្នុងកម្រិតថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិដូចជា៖ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន (ភ្នាក់ងារទឹកបារាំង) គម្រោង ការរៀបចំបង្កើតវេទិកាអភិរក្សបរិស្ថានធនធានធម្មជាតិបឹងទន្លេសាប គម្រោងកិច្ចសហប្រតិបត្តិការគ្រប់គ្រង ធនធានទឹកចម្រុះឆ្លងដែនរវាងបឹងទន្លេសាប(កម្ពុជា)និងអាងសុងខ្លា(ថៃ)កិច្ចសហការផ្លាស់ប្តូរចែករំលែក ការយល់ដឹង International Lake Environment Committee Foundation (Japan) និងគម្រោង Fisher Catch Monitoring in the Provinces around Tonle Sap Lake, Cambodia (Mekong River Commission) និងកំពុងពិចារណាអត្ថប្រយោជន៍ក្នុងការចូលជាសមាជិក Global Water Partnership។

ការយកចិត្តទុកដាក់ជំរុញប្រសិទ្ធភាពការងារបច្ចេកទេស និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការ កៀរគរជំនួយពីដៃគូអភិវឌ្ឍន៍នានា អាជ្ញាធរទន្លេសាបក៏បានខិតខំប្រឹងប្រែងប្រតិបត្តិការងារប្រចាំថ្ងៃនៅក្នុង អង្គភាពដើម្បីជំរុញប្រសិទ្ធភាពដំណើរការរៀបចំតាមដានផែនការសកម្មភាព និងការសម្របសម្រួលបញ្ជ្រាប ផែនការថវិកាអង្គភាពចូលក្នុងថវិកាកម្មវិធីប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល។ ក្នុងនោះការគ្រប់គ្រងរដ្ឋបាល និង បុគ្គលិកបានយកចិត្តទុកដាក់លើកទឹកចិត្តមន្ត្រីរាជការ មន្ត្រីកិច្ចសន្យា និងថ្នាក់ដឹកនាំក្រោមឱវាទ និងការក សាងអភិវឌ្ឍសមត្ថភាពដល់មន្ត្រីជំនាញ និងអ្នកពាក់ព័ន្ធទទួលបាននូវការបណ្តុះបណ្តាល ទាំងនៅក្នុង និង ក្រៅប្រទេស។

ក្នុងការជំរុញប្រសិទ្ធភាពនៃដំណើរការរៀបចំតាមដានផែនការយុទ្ធសាស្ត្រ បានបង្កើតឲ្យមានការ ប្រជុំពិគ្រោះយោបល់តាមដាន ដើម្បីពិនិត្យពីវឌ្ឍនភាពការងារទាំងចំណុចខ្សោយ ចំណុចខ្លាំង និងបញ្ហា ប្រឈមក្នុងការវាយតម្លៃពីលទ្ធផលសម្រេចបាន សម្រាប់រៀបចំបច្ចុប្បន្នភាពសកម្មភាពការងារ និងផែនការ

សកម្មភាពជាបន្តបន្ទាប់។ ផ្អែកលើមូលដ្ឋានសកម្មភាពការងារ និងតួនាទីភារកិច្ចទទួលខុសត្រូវក្នុងបទប្បញ្ញត្តិ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពការងារ បានប្រើប្រាស់សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកា ដើម្បីសមាហរណកម្មចូលក្នុងកម្មវិធីប្រចាំឆ្នាំដែលធ្វើឲ្យកញ្ចប់ថវិកាគ្រោងចំណាយបច្ចុប្បន្នបានកើនឡើងសរុបចំនួន ៤,៣០០លានរៀលក្នុង១ឆ្នាំ។

ការងារគ្រប់គ្រងរដ្ឋបាល និងបុគ្គលិកអាជ្ញាធរទន្លេសាប បានពង្រឹងការយកចិត្តទុកដាក់ខ្ពស់ និងបានធ្វើការណែនាំជាប្រចាំដល់មន្ត្រីរាជការក្រោមឱវាទឲ្យទទួលខុសត្រូវចំពោះកិច្ចការរដ្ឋបាល ដើម្បីសម្រួលឲ្យដំណើរការការងារប្រចាំថ្ងៃប្រកបដោយប្រសិទ្ធភាពដូចជា៖ ការគ្រប់គ្រងចរន្តលិខិតចេញ-ចូល គឺបានធ្វើការពិនិត្យរាល់ខ្លឹមសារ អត្ថន័យលិខិតបទដ្ឋានគតិយុត្តនានា និងសម្របសម្រួលលិខិតចេញ-ចូលពាក់ព័ន្ធក្នុងអង្គភាព។ ក្នុងនោះដែរបានជំរុញឲ្យមានការយកចិត្តទុកដាក់ទៅលើការថែទាំ ជួសជុលនូវទ្រព្យសម្បត្តិរដ្ឋ និងសម្របសម្រួលដល់ការផ្គត់ផ្គង់សម្ភារបរិក្ខារជាលក្ខណៈរដ្ឋបាល និងលក្ខណៈបច្ចេកទេសជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទ ដើម្បីឲ្យដំណើរការនៃការងារមានប្រសិទ្ធភាព។ ក្នុងដំណើរការសកម្មភាពគ្រប់គ្រងបុគ្គលិក គឺបានផ្តល់នូវសេចក្តីណែនាំ និងក្រើនរំលឹកជាបន្តបន្ទាប់ចំពោះការពង្រឹងតួនាទីភារកិច្ចក្នុងនាមជាមន្ត្រីរាជការដែលកំពុងបម្រើការងារនៅក្នុងអង្គភាពនៃអាជ្ញាធរទន្លេសាប ដោយអនុលោមគោរពតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

ការបំពេញការងារស្នូលអង្គភាពរួមជាមួយការចុះអនុវត្តការងារជាក់ស្តែង បើទោះបីជាចំនួនមន្ត្រីដែលកំពុងបម្រើការងារបច្ចុប្បន្នមានការយល់ដឹងនៅមានកម្រិតក៏ដោយ ក៏អាជ្ញាធរទន្លេសាបបានប្រឹងប្រែងយកចិត្តទុកដាក់លើមន្ត្រីរាជការ ដោយមានការលើកទឹកចិត្តជូនដល់មន្ត្រីរាជការដូចជា តំឡើងតួនាទី តំឡើងឋានន្តរស័ក្តិ តំឡើងកាំប្រាក់ និងស្នើសុំផ្តល់គ្រឿងឥស្សរិយយសជាដើម។ ក្នុងនោះដែរ ក៏បានជំរុញលើកកម្ពស់ដល់ការពង្រឹងការយល់ដឹងដល់មន្ត្រីរាជការបន្ថែមដោយបានគិតគូរដល់ការបង្កើនសមត្ថភាព និងអភិវឌ្ឍចំណេះដឹងបន្ថែមទៀតដល់មន្ត្រីរាជការ តាមរយៈការបញ្ជូនមន្ត្រីឲ្យទៅចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស។

## ២.២- បញ្ហាប្រឈម

ជាមួយវឌ្ឍនភាពការអនុវត្តផែនការយុទ្ធសាស្ត្រ ២០១៦-២០២០ ខាងលើ អាជ្ញាធរទន្លេសាប ក៏បានជួបប្រទះនូវចំណុចខ្វះខាត និងបញ្ហាប្រឈមមួយចំនួន រួមមាន៖

- ការចូលរួមគាំទ្រ និងសហការនៅមានកម្រិត ពីបណ្តាក្រសួង/ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធទាំងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់សហគមន៍មូលដ្ឋាន និងថ្នាក់តំបន់
- ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងការគ្រប់គ្រងធនធានមនុស្សមិនទាន់អាចឆ្លើយតបបានពេញលេញទៅតាមសេចក្តីត្រូវការនៅឡើយជាពិសេសធនធានមនុស្សទៅតាមជំនាញនីមួយៗ
- ចំនួនមន្ត្រីរាជការនៅក្នុងរចនាសម្ព័ន្ធការងាររបស់នាយកដ្ឋាននីមួយៗនៅមានចំនួនតិច ដែលមិនទាន់ឆ្លើយតបនឹងទំហំការងារបានពេញលេញនៅឡើយ

- ការផ្តល់អាទិភាព និងការចូលរួមក្នុងការអនុវត្តការងាររបស់មន្ត្រីរាជការនៅមានកម្រិត
- ចំនួនមន្ត្រីរាជការជាស្ត្រីនៅមានកម្រិត
- ការប្រែប្រួលអាកាសធាតុ ពិសេសលើការប្រែប្រួលរបបជលសាស្ត្រដែលប៉ះពាល់ដល់សកម្មភាពស្រាវជ្រាវមួយចំនួនមិនអាចអនុវត្តន៍បានពេញលេញ
- ការកើតឡើង និងរីករាលដាលនៃជម្ងឺកូវីដ-១៩ បានជះឥទ្ធិពលដល់ការអនុវត្តផែនការយុទ្ធសាស្ត្រ (បន្ថយសកម្មភាពចុះអនុវត្តន៍ការងារប្រចាំថ្ងៃមួយចំនួន)
- ការអនុវត្តការងាររដ្ឋបាល និងបច្ចេកទេស គឺត្រូវពឹងផ្អែកលើសម្ភារបច្ចេកទេសទំនើបកម្មក៏ប៉ុន្តែការប្រើប្រាស់នូវកញ្ចប់ថវិកាសម្រាប់ការចំណាយ និងដំណើរការសកម្មភាពនៅមានកម្រិត
- ការគ្រប់គ្រងទិន្នន័យលើការសិក្សាស្រាវជ្រាវតាមដាន និងឯកសារផ្សេងៗនាពេលកន្លងមកពុំទាន់មានការប្រមូលផ្តុំជាប្រព័ន្ធទិន្នន័យរួមសម្រាប់ប្រើប្រាស់នៅអាជ្ញាធរទន្លេសាប ក៏ដូចជាការផ្សព្វផ្សាយពុំទាន់មានភាពទូលំទូលាយនៅឡើយ
- ការរៀបចំវគ្គបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រី គឺពុំបានឆ្លើយតបទាំងស្រុងទៅតាមតម្រូវការជាក់ស្តែងរបស់នាយកដ្ឋានជំនាញនីមួយៗ ព្រមទាំងអគ្គលេខាធិការដ្ឋានទាំងមូល
- ការចូលរួមសិក្ខាសាលា សន្និសីទក្នុង និងក្រៅប្រទេសពុំបានឆ្លើយតបពេញលេញទៅតាមតម្រូវការរបស់ស្ថាប័ននៅឡើយ ក៏ដូចជាការផ្សព្វផ្សាយនូវលទ្ធផលនៃកិច្ចប្រជុំ។

រាល់សមិទ្ធផល បញ្ហាប្រឈម និងចំណុចខ្វះខាតនៃការអនុវត្តផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាបរយៈពេល៥ឆ្នាំ ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២០ គឺជាធាតុចូលមួយដ៏សំខាន់សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០២១-២០២៥។

# ផ្នែកទី៣

# ផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០២១-២០២៥

ការកំណត់នូវចក្ខុវិស័យ នៃផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាបគឺស្របជាមួយអាណត្តិ និងតួនាទីភារកិច្ចដែលបានកំណត់នៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប។

ជាក់ស្តែងបច្ចុប្បន្នតំបន់បឹងទន្លេសាបត្រូវបានទទួលរងនូវការគំរាមកំហែងយ៉ាងខ្លាំងតាមរយៈកត្តាមនុស្ស និងកត្តាប្រែប្រួលអាកាសធាតុ ដែលតម្រូវឲ្យអាជ្ញាធរទន្លេសាបចាំបាច់ពង្រឹង និងពង្រីកការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រទំនើបដើម្បីកំណត់រាល់មូលហេតុបញ្ហាប្រឈមនិងដំណោះស្រាយផ្សេងៗនៅក្នុងតំបន់បឹងទន្លេសាប។

យោងលើអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមកិត្តិបណ្ឌិត **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាបសំដៅឲ្យអាជ្ញាធរទន្លេសាបពង្រឹង និងពង្រីកការសិក្សាស្រាវជ្រាវលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាបប្រកបដោយចីរភាព។

ហេតុដូចនេះ សម្រាប់នីតិកាលទី៦ និងជាលើកទី២ នៃការរៀបចំផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាបបានកំណត់យកចក្ខុវិស័យផ្តោតលើការសិក្សាស្រាវជ្រាវអមដោយ បេសកកម្ម គោលដៅយុទ្ធសាស្ត្រ ទិសដៅយុទ្ធសាស្ត្រ និងសកម្មភាពយុទ្ធសាស្ត្រដែលជាគ្រោងឆ្អឹងដ៏រឹងមាំ និងប្រទាក់ក្រឡាគ្នា រួមមានជាអាទិ៍៖

ដ្យាក្រាមទី២ គំនូសបំព្រួញរចនាសម្ព័ន្ធចក្ខុវិស័យ បេសកកម្ម និងសសរស្តម្ភ



## ៣.១- ចក្ខុវិស័យ និងបេសកកម្ម

៣.១.១. ចក្ខុវិស័យ ក្របខណ្ឌផែនការយុទ្ធសាស្ត្រ សម្រាប់អាជ្ញាធរទន្លេសាប បង្កើតឡើងដោយផ្អែកលើតួនាទី ភារកិច្ច ទស្សនវិស័យ និងបេសកកម្ម ដែលរាជរដ្ឋាភិបាលបានកំណត់ " **អាជ្ញាធរទន្លេសាបជាស្ថាប័នថ្នាក់ជាតិមួយក្នុងការសិក្សាស្រាវជ្រាវ និងសម្របសម្រួលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាបប្រកបដោយចីរភាព** " ។

៣.១.២. បេសកកម្ម ដើម្បីសម្រេចបាននូវចក្ខុវិស័យច្បាស់លាស់ខាងលើ **បេសកកម្មចំនួន៣** ត្រូវបានកំណត់ដូចខាងក្រោម៖

(១) ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រ និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍប្រកបដោយចីរភាព

(២) សម្របសម្រួល និងប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើឲ្យប្រសើរឡើងវិញនូវធនធានធម្មជាតិនៃតំបន់បឹងទន្លេសាប

(៣) ពង្រឹងធនធានមនុស្ស មូលដ្ឋានទិន្នន័យ និងទំនាក់ទំនងកិច្ចសហប្រតិបត្តិការ។

## ៣.២- គោលដៅយុទ្ធសាស្ត្រ និងគោលបំណង

### ៣.២.១. គោលដៅយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រនេះមាន **គោលដៅយុទ្ធសាស្ត្រចំនួន៤** គាំទ្រដល់បេសកកម្មខាងលើរួមមាន៖

១- ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រជាមូលដ្ឋានក្នុងតំបន់បឹងទន្លេសាប

២- ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា

៣- លើកកម្ពស់ប្រសិទ្ធភាពនៃការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍

៤- ពង្រឹងការគ្រប់គ្រងអង្គភាព/ស្ថាប័ន និងមូលដ្ឋានចំណេះដឹងលើការសិក្សាស្រាវជ្រាវ។

### ៣.៣.២. គោលបំណង

ផែនការយុទ្ធសាស្ត្រនេះ មានគោលបំណងរួម គឺពង្រឹងការសិក្សាស្រាវជ្រាវ និងសម្របសម្រួលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាបប្រកបដោយចីរភាព រវាងអាជ្ញាធរទន្លេសាបជាមួយភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើឲ្យប្រសើរឡើងវិញនូវធនធានធម្មជាតិក្នុងតំបន់បឹងទន្លេសាប។

## ៣.៣- បារ៉មិតា និងរចនាសម្ព័ន្ធរបស់អាជ្ញាធរទន្លេសាប

### ៣.៣.១. បារមិតា

ឯកឧត្តមកិត្តិបណ្ឌិត **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប សម្រាប់នីតិកាលទី៦ នេះ បានកំណត់យកនូវបារមិតាចំនួន៣ ដូចខាងក្រោម៖

១) ជាស្ថាប័នថ្នាក់ជាតិមួយក្នុងការសិក្សាស្រាវជ្រាវតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

២) ជាស្ថាប័នគ្រប់គ្រងទិន្នន័យ ព័ត៌មាន និងឯកសារស្រាវជ្រាវនៃតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

៣) ការពារផលប្រយោជន៍មន្ត្រីរាជការ និងសុខដុមនីយកម្ម។

### ៣.៣.២. រចនាសម្ព័ន្ធរបស់អាជ្ញាធរទន្លេសាប

អាជ្ញាធរទន្លេសាប ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ អមដោយទីប្រឹក្សា និងជំនួយការមួយចំនួនតាមការចាំបាច់ និងមានអគ្គលេខាធិការដ្ឋានជាសេនាធិការផ្ទាល់ដើម្បីចាត់ចែងការងារទូទៅប្រចាំថ្ងៃ និងមាននាយកដ្ឋានក្រោមឱវាទចំនួន៤ រួមមាន៖

១) នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ

២) នាយកដ្ឋានធនធានធម្មជាតិ

៣) នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស

៤) នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ។

ដ្យាក្រាមទី៣ រចនាសម្ព័ន្ធរបស់អាជ្ញាធរទន្លេសាប



## ៣.៤- ទិសដៅយុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រដែលជាលទ្ធផលរំពឹងទុកទាំង៤ខាងលើ អាជ្ញាធរទន្លេសាបបានកំណត់នូវទិសដៅយុទ្ធសាស្ត្រចំនួន១០ ដែលមានជាអាទិ៍៖

១- ជំរុញប្រសិទ្ធភាព និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវតាមដានលើអេកូស៊ីស្តែមតំបន់បឹងទន្លេសាប

២- ពង្រឹងប្រសិទ្ធភាព នៃការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍ ព្រមទាំងការតាមដានត្រួតពិនិត្យសកម្មភាពដែលបាន និងកំពុងអនុវត្ត

៣- ពង្រឹងការតាមដានជាសកម្មលើផលប៉ះពាល់លើអេកូស៊ីស្តែម និងសម្របសម្រួលតាមការប្រែប្រួលអាកាសធាតុតំបន់បឹងទន្លេសាបទាំងលើធនធានធម្មជាតិ ទាំងលើវិស័យសង្គម/សេដ្ឋកិច្ច

៤- ពង្រឹងប្រសិទ្ធភាព និងការរៀបចំគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់អាជ្ញាធរទន្លេសាប

៥- ពង្រឹងកិច្ចសហប្រតិបត្តិការ និងការគ្រប់គ្រងលើការចែករំលែកព័ត៌មានវិទ្យា

៦- ជំរុញប្រសិទ្ធភាពយន្តការសម្របសម្រួល និងប្រឹក្សាយោបល់

៧- លើកកម្ពស់ប្រសិទ្ធភាពកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍

៨- លើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងដំណើរការស្ថាប័នប្រកបដោយចីរភាព

៩- អភិវឌ្ឍន៍គោលនយោបាយយុទ្ធសាស្ត្រ និងកសាងផែនការសម្រាប់តំបន់បឹងទន្លេសាប

១០-ពង្រឹងសមត្ថភាពមន្ត្រីរាជការលើការសិក្សាស្រាវជ្រាវ តាមដានលើប្រធានបទនីមួយៗតាមគោលដៅរបស់អាជ្ញាធរទន្លេសាប។

## ៣.៥- សកម្មភាពយុទ្ធសាស្ត្រ (សកម្មភាពគន្លឹះ)

ដើម្បីជាគ្រឹះក្នុងការសម្រេចតាមចក្ខុវិស័យ បេសកកម្ម គោលដៅ ទិសដៅយុទ្ធសាស្ត្ររបស់ផែនការយុទ្ធសាស្ត្រនេះ សកម្មភាពយុទ្ធសាស្ត្រដែលជាកត្តាគន្លឹះ និងមានភាពប្រទាក់ក្រឡាគ្នាចំនួន២៧ សកម្មភាពគន្លឹះត្រូវបានកំណត់ដែលមានជាអាទិ៍៖

### ៣.៥.១. ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រជាមូលដ្ឋានក្នុងតំបន់បឹងទន្លេសាប

៣.៥.១.១. ជំរុញប្រសិទ្ធភាព និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវតាមដានលើអេកូស៊ីស្តែមតំបន់បឹងទន្លេសាប

១) ពិនិត្យឡើងវិញនូវសកម្មភាពក្នុងការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ

២) ធ្វើការកំណត់ដែនវិសាលភាពដែលត្រូវចុះធ្វើការសិក្សាស្រាវជ្រាវ

៣) សិក្សាស្រាវជ្រាវ និងវាយតម្លៃលើបច្ចុប្បន្នភាពធនធានធម្មជាតិតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ។

៣.៥.១.២. ពង្រឹងប្រសិទ្ធភាពនៃការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍព្រមទាំងការតាមដានត្រួតពិនិត្យសកម្មភាពដែលបាន និងកំពុងអនុវត្ត

១) តាមដានត្រួតពិនិត្យគម្រោងអភិវឌ្ឍន៍ដែលមានស្រាប់ និងកំពុងអនុវត្តក្នុងតំបន់បឹងទន្លេសាប

២) កំណត់តម្រូវការជាមូលដ្ឋាន និងតាមដានពិនិត្យជាប្រចាំរាល់បញ្ហាដែលជួបប្រទះនៅតាមទីតាំងក្នុងតំបន់២ តំបន់៣ ជុំវិញបឹងទន្លេសាប។

៣.៥.១.៣. ពង្រឹងការតាមដានជាសកម្មលើផលប៉ះពាល់នៃអេកូស៊ីសស្តែម និងសម្របសម្រួលតាមការប្រែប្រួលអាកាសធាតុតំបន់បឹងទន្លេសាបទាំងលើធនធានធម្មជាតិ ទាំងលើវិស័យសង្គម/សេដ្ឋកិច្ច

១) សិក្សាតាមដានលើរបបជលសាស្ត្រ គុណភាពទឹក ព្រៃលិចទឹក ជីវចម្រុះ (ធនធានជលផល ប្រភេទFlora and Fauna តាមទីតាំង និងរដូវកាល) សេដ្ឋកិច្ចសង្គម និងការរស់នៅរបស់ប្រជាជនដែលមានភាពទំនាក់ទំនងនឹងសម្ពាធនៃការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍ

២) ពង្រឹងការសិក្សាតាមដានប្រភេទព្រៃលិចទឹកតំបន់៣ និងអធិការកិច្ចដែនអភិរក្សព្រៃលិចទឹកតំបន់៣។

### ៣.៥.២. ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា

៣.៥.២.១. ពង្រឹងប្រសិទ្ធភាព និងការរៀបចំគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់អាជ្ញាធរទន្លេសាប

១) ជំរុញប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងព័ត៌មានវិទ្យាអាជ្ញាធរទន្លេសាប

២) រៀបចំកសាងផលិតរបាយការណ៍ ស្តីពីស្ថានភាពបឹងទន្លេសាប

៣) ផលិតរូបភាពផែនទី/រូបថតលើអាកាស និងធ្វើបច្ចុប្បន្នភាពនៃតំបន់បឹងទន្លេសាប។

៣.៥.២.២. ពង្រឹងកិច្ចសហប្រតិបត្តិការ និងការគ្រប់គ្រងលើការចែករំលែកព័ត៌មានវិទ្យា

១) ជំរុញកិច្ចសហប្រតិបត្តិការក្នុងការផ្លាស់ប្តូរចំណេះដឹង បទពិសោធន៍ ព្រមទាំងផលិតឯកសារស្រាវជ្រាវ

២) កសាង និងពង្រឹងទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍លើការសិក្សាស្រាវជ្រាវ និងផ្នែកបច្ចេកទេស

៣) រៀបចំប្រព័ន្ធព័ត៌មានវិទ្យា និងបណ្តាញទំនាក់ទំនងការងារក្នុងភាពជាដៃគូក្នុងការគ្រប់គ្រង និងអភិវឌ្ឍធនធានធម្មជាតិតំបន់បឹងទន្លេសាប។

### ៣.៥.៣. លើកកម្ពស់ប្រសិទ្ធភាពនៃការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍

៣.៥.៣.១. ជំរុញប្រសិទ្ធភាពយន្តការសម្របសម្រួល និងប្រឹក្សាយោបល់

១) ស្វែងយល់ និងកំណត់ហេតុលើបញ្ហាវិវាទក្នុងតំបន់បឹងទន្លេសាប

២) លើកកម្ពស់យន្តការសម្របសម្រួល និងកិច្ចទំនាក់ទំនង
៣) ពង្រឹងការប្រឹក្សាយោបល់អន្តរវិស័យ និងដំណោះស្រាយ។

៣.៥.៣.២. លើកកម្ពស់ប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍
១) ជំរុញកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលជាមួយអន្តរក្រសួង/ស្ថាប័ន និងដៃគូអភិវឌ្ឍន៍
២) ជំរុញកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលរវាងសហគមន៍មូលដ្ឋានក្នុងតំបន់បឹងទន្លេសាប
៣) ជំរុញលើការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន លើមុខរបរសមស្របក្រៅពីធនធានធម្មជាតិក្នុងតំបន់បឹងទន្លេសាបប្រកបដោយចីរភាព។

### ៣.៥.៤. ពង្រឹងការគ្រប់គ្រងអង្គភាព/ស្ថាប័ន និងមូលដ្ឋានចំណេះដឹងលើការសិក្សាស្រាវជ្រាវ

៣.៥.៤.១. លើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងដំណើរការស្ថាប័នប្រកបដោយចីរភាព
១) កសាងសមត្ថភាព និងពង្រឹងអង្គភាព/ស្ថាប័ន
២) ការរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់អាជ្ញាធរទន្លេសាប។

៣.៥.៤.២. អភិវឌ្ឍន៍គោលនយោបាយយុទ្ធសាស្ត្រ និងកសាងផែនការសម្រាប់តំបន់បឹងទន្លេសាប
១) រៀបចំកសាងផែនការយុទ្ធសាស្ត្រសម្រាប់តំបន់បឹងទន្លេសាប
២) រៀបចំគោលនយោបាយការគ្រប់គ្រង និងអភិវឌ្ឍតំបន់បឹងទន្លេសាប
៣) រៀបចំកសាងផែនការចង្អុលបង្ហាញ/ផែនការមេសម្រាប់តំបន់បឹងទន្លេសាប។

៣.៥.៤.៣. ពង្រឹងសមត្ថភាពមន្ត្រីរាជការលើការសិក្សាស្រាវជ្រាវតាមជានលើប្រធានបទនីមួយៗ តាមគោលដៅរបស់អាជ្ញាធរទន្លេសាប
១) លើកកម្ពស់ការយល់ដឹងលើប្រធានបទនៃការសិក្សាស្រាវជ្រាវដែលជាតម្រូវការជាក់ស្តែងរបស់អាជ្ញាធរទន្លេសាប
២) លើកកម្ពស់យេនឌ័រក្នុងវិស័យធនធានធម្មជាតិ
៣) ធ្វើឲ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងរបស់អាជ្ញាធរទន្លេសាប ក្នុងការអនុវត្តតួនាទីភារកិច្ចប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងភាពច្នៃប្រឌិតខ្ពស់។

## តារាងម៉ាទ្រិកទី១ សកម្មភាពយុទ្ធសាស្ត្រ( សកម្មភាពគន្លឹះ )

| គោលដៅ/ទិសដៅ | | សកម្មភាពគន្លឹះ/ធាតុចេញ | អាទិភាព (ខ្ពស់ មធ្យម ទាប) |
|---|---|---|---|
| គោលដៅយុទ្ធសាស្ត្រ១. ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រជាមូលដ្ឋានក្នុងតំបន់បឹងទន្លេសាប | | | |
| ១.១ | ជំរុញប្រសិទ្ធភាព និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវតាមដានលើអេកូស៊ីសស្តែម តំបន់បឹងទន្លេសាប | ពិនិត្យឡើងវិញនូវសកម្មភាពក្នុងការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ | ខ្ពស់ |
| | | ធ្វើការកំណត់ដែនវិសាលភាពដែលត្រូវចុះធ្វើការសិក្សាស្រាវជ្រាវ | មធ្យម |
| | | សិក្សាស្រាវជ្រាវ និងវាយតម្លៃលើបច្ចុប្បន្នភាពធនធានធម្មជាតិតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ | ខ្ពស់ |
| ១.២ | ពង្រឹងប្រសិទ្ធភាពនៃការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍ ព្រមទាំងការតាមដានត្រួតពិនិត្យសកម្មភាពដែលបាន និងកំពុងអនុវត្ត | តាមដានត្រួតពិនិត្យគម្រោងដែលមានស្រាប់ និងកំពុងអនុវត្តក្នុងតំបន់បឹងទន្លេសាប | មធ្យម |
| | | កំណត់តម្រូវការជាមូលដ្ឋាន និងតាមដានពិនិត្យជាប្រចាំរាល់បញ្ហាដែលជួបប្រទះនៅតាមទីតាំងក្នុងតំបន់២ និងតំបន់៣ ជុំវិញតំបន់បឹងទន្លេសាប | មធ្យម |
| ១.៣ | ពង្រឹងការតាមដានជាសកម្មលើផលប៉ះពាល់លើអេកូស៊ីសស្តែម និងសម្របសម្រួលតាមការប្រែប្រួលអាកាសធាតុ តំបន់បឹងទន្លេសាបទាំងលើធនធានធម្មជាតិ ទាំងលើវិស័យសង្គម/សេដ្ឋកិច្ច | សិក្សាតាមដានលើរបបជលសាស្ត្រ គុណភាពទឹក ព្រៃលិចទឹក ជីវចម្រុះ( ធនធានជលផល ប្រភេទ Flora and Fauna តាមទីតាំង និងរដូវកាល ) សេដ្ឋកិច្ចសង្គម និងការរស់នៅរបស់ប្រជាជនដែលមានភាពទំនាក់ទំនងនឹងសម្ពាធនៃការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍ | ខ្ពស់ |
| | | ពង្រឹងការសិក្សាតាមដានប្រភេទព្រៃលិចទឹកតំបន់៣ និងអធិការកិច្ចដែនអភិរក្សព្រៃលិចទឹកតំបន់៣ | ខ្ពស់ |
| គោលដៅយុទ្ធសាស្ត្រទី២. ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា | | | |
| | ពង្រឹងប្រសិទ្ធភាព និងការ | ជំរុញប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រទិន្នន័យ | ខ្ពស់ |

| | | | |
|---|---|---|---|
| ២.១ | រៀបចំគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់អាជ្ញាធរទន្លេសាប | និងព័ត៌មានវិទ្យាអាជ្ញាធរទន្លេសាប | |
| | | រៀបចំកសាងផលិតរបាយការណ៍ ស្ដីពីស្ថានភាពតំបន់បឹងទន្លេសាប | ខ្ពស់ |
| | | ផលិតរូបភាពផែនទី/រូបថតលើអាកាស និងធ្វើបច្ចុប្បន្នភាពនៃតំបន់បឹងទន្លេសាប | ខ្ពស់ |
| ២.២ | ពង្រឹងកិច្ចសហប្រតិបត្តិការ និងការគ្រប់គ្រងលើការចែករំលែកព័ត៌មានវិទ្យា | ជំរុញកិច្ចសហប្រតិបត្តិការក្នុងការផ្លាស់ប្តូរចំណេះដឹង បទពិសោធន៍ ព្រមទាំងផលិតឯកសារស្រាវជ្រាវ | មធ្យម |
| | | កសាង និងពង្រឹងទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍លើការសិក្សាស្រាវជ្រាវ និងផ្នែកបច្ចេកទេស | ខ្ពស់ |
| | | រៀបចំប្រព័ន្ធព័ត៌មានវិទ្យា និងបណ្ដាញទំនាក់ទំនងការងារក្នុងភាពជាដៃគូលើការគ្រប់គ្រង និងអភិវឌ្ឍធនធានធម្មជាតិតំបន់បឹងទន្លេសាប | មធ្យម |
| | | | |
| **គោលដៅយុទ្ធសាស្ត្រទី៣. លើកកម្ពស់ប្រសិទ្ធភាពនៃការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍** | | | |
| ៣.១ | ជំរុញប្រសិទ្ធភាព យន្តការសម្របសម្រួល និងប្រឹក្សាយោបល់ | ស្វែងយល់ និងកំណត់ហេតុលើបញ្ហាវិវាទក្នុងតំបន់បឹងទន្លេសាប | មធ្យម |
| | | លើកកម្ពស់យន្តការសម្របសម្រួល និងកិច្ចទំនាក់ទំនង | មធ្យម |
| | | ពង្រឹងការប្រឹក្សាយោបល់អន្តរវិស័យ និងដំណោះស្រាយ | ខ្ពស់ |
| ៣.២ | លើកកម្ពស់ប្រសិទ្ធភាពកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ | ជម្រុញកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលជាមួយអន្តរក្រសួង/ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ | មធ្យម |
| | | ជំរុញកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលជាមួយសហគមន៍មូលដ្ឋានក្នុងតំបន់បឹងទន្លេសាប | មធ្យម |
| | | ជំរុញការលើកកម្ពស់ជីវភាពសហគមន៍ | មធ្យម |

| | | | |
|---|---|---|---|
| | | មូលដ្ឋានលើមុខរបរសមស្របក្រៅពីធនធានធម្មជាតិក្នុងតំបន់បឹងទន្លេសាបប្រកបដោយចីរភាព | |
| គោលដៅយុទ្ធសាស្ត្រទី៤. ពង្រឹងការគ្រប់គ្រងអង្គភាព/ស្ថាប័ន និងមូលដ្ឋានចំណេះដឹងលើការសិក្សាស្រាវជ្រាវ | | | |
| ៤.១ | លើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងដំណើរការស្ថាប័នប្រកបដោយចីរភាព | កសាងសមត្ថភាព និងការពង្រឹងអង្គភាពស្ថាប័ន | ខ្ពស់ |
| | | ការរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់អាជ្ញាធរទន្លេសាប | ខ្ពស់ |
| ៤.២ | អភិវឌ្ឍន៍គោលនយោបាយ យុទ្ធសាស្ត្រ និងកសាងផែនការសម្រាប់តំបន់ទន្លេសាប | រៀបចំកសាងផែនការយុទ្ធសាស្ត្រសម្រាប់តំបន់បឹងទន្លេសាប | ខ្ពស់ |
| | | រៀបចំគោលនយោបាយគ្រប់គ្រងអាង និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាប | ខ្ពស់ |
| | | រៀបចំកសាងផែនការចង្អុលបង្ហាញ/ផែនការមេសម្រាប់តំបន់បឹងទន្លេសាប | ខ្ពស់ |
| ៤.៣ | ពង្រឹងសមត្ថភាពមន្ត្រីលើការសិក្សាស្រាវជ្រាវតាមដានលើប្រធានបទនីមួយៗតាមគោលដៅរបស់អាជ្ញាធរទន្លេសាប | លើកកម្ពស់ការយល់ដឹងលើប្រធានបទនៃការសិក្សាស្រាវជ្រាវដែលជាតម្រូវការជាក់ស្តែងរបស់អាជ្ញាធរទន្លេសាប | មធ្យម |
| | | លើកកម្ពស់យេនឌ័រក្នុងវិស័យធនធានធម្មជាតិ | ខ្ពស់ |
| | | ធ្វើឲ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងរបស់អាជ្ញាធរទន្លេសាបក្នុងការអនុវត្តតួនាទី ភារកិច្ចប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងភាពច្នៃប្រឌិតខ្ពស់ | ខ្ពស់ |

## តារាងម៉ាទ្រិកទី២ បង្ហាញសង្ខេបអំពីទិសដៅយុទ្ធសាស្ត្រ សូចនាករ និងចំណុចដៅ

| ទិសដៅយុទ្ធសាស្ត្រ | សូចនាករ | ចំណុចដៅ |
|---|---|---|
| ១.ជំរុញប្រសិទ្ធភាព និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវតាមដានលើអេកូស៊ីសស្តែមតំបន់បឹងទន្លេសាប | - ផែនការ/កម្មវិធីសកម្មភាពសិក្សាស្រាវជ្រាវ<br>- របាយការណ៍វិភាគ និងលទ្ធផលនៃការចុះសិក្សាស្រាវជ្រាវពីបច្ចុប្បន្នភាពស្ថានភាពតំបន់បឹងទន្លេសាបប្រចាំឆ្នាំ<br>- ព័ត៌មានទិន្នន័យគោល Raw data and Data Processing ត្រូវបានចងក្រងរក្សាទុក និងប្រើប្រាស់តាមសកម្មភាពសិក្សាស្រាវជ្រាវ<br>- ទិន្នន័យ និងព័ត៌មានភូមិសាស្ត្រតំបន់បឹងទន្លេសាបត្រូវបានបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យតំបន់បឹងទន្លេសាប | - សកម្មភាពសិក្សាស្រាវជ្រាវត្រូវបានដាក់បញ្ចូលក្នុងផែនការសកម្មភាពប្រចាំឆ្នាំ<br>- កម្រងរបាយការណ៍លទ្ធផលចុះសិក្សាស្រាវជ្រាវរបស់នាយកដ្ឋានក្រោមឱវាទអាជ្ញាធរទន្លេសាប<br>- ឯកសារបោះពុម្ពផ្សព្វផ្សាយរបាយការណ៍បច្ចេកទេស លទ្ធផលស្រាវជ្រាវពីបច្ចុប្បន្នភាពស្ថានភាពតំបន់បឹងទន្លេសាបប្រចាំឆ្នាំ<br>- ចំណុចទីតាំងភូមិសាស្ត្រ ព្រំប្រទល់ និងផែនទីវិសាលភាពតំបន់បឹងទន្លេសាបត្រូវបានកំណត់ និងសេចក្តីព្រាង |
| ២.ពង្រឹងប្រសិទ្ធភាពនៃការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍព្រមទាំងការតាមដានត្រួតពិនិត្យសកម្មភាពដែលបាន និងកំពុងអនុវត្ត | - បញ្ជីគម្រោងពាក់ព័ន្ធតំបន់ទន្លេសាប<br>- ផែនការ/កម្មវិធីសកម្មភាពការងារចុះប្រមូលចងក្រង និងសិក្សាស្រាវជ្រាវ<br>- របាយការណ៍ការវិភាគ និងការផ្តល់យោបល់ពីប្រសិទ្ធភាពរបស់គម្រោងបន្សុីជាមួយគោលនយោបាយរបស់រាជរដ្ឋាភិបាល<br>- ការលើកកម្ពស់ និងការពង្រឹងសមត្ថភាពរបស់មន្ត្រី | - ចំនួនគម្រោងបញ្ចប់ កំពុងដំណើរការ និងគ្រោងដំណើរការ<br>- ផែនការសកម្មភាពប្រចាំឆ្នាំ<br>- គម្រោង និងទីតាំងគម្រោងចុះសិក្សាស្រាវជ្រាវ<br>- ការយល់ដឹង និងសមត្ថភាពជំនាញរបស់មន្ត្រីរាជការ<br>- របាយការណ៍សិក្សាស្វែងយល់ពីប្រសិទ្ធភាពនៃការអនុវត្តគម្រោងតាមតំបន់គោលដៅចុះសិក្សាស្រាវជ្រាវ<br>- វគ្គលើកកម្ពស់សមត្ថភាពមន្ត្រីរាជការ អ.ទ.ស ២ដង/ឆ្នាំ |
| ៣. ពង្រឹងការតាមដានជាសកម្មលើផលប៉ះពាល់លើ | - របាយការណ៍សិក្សាស្រាវជ្រាវអេកូស៊ីសស្តែមបឹងទន្លេសាប | - ទិន្នន័យអេកូស៊ីសស្តែម (ជីវចម្រុះ ធនធានជលផល គីមី ជីវសាស្ត្រ ....។ល។) |

| | | |
|---|---|---|
| អេកូស៊ីសស្តែម និងសម្រប សម្រួលតាមការប្រែប្រួល អាកាសធាតុតំបន់បឹងទន្លេ សាបទាំងលើធនធានធម្ម ជាតិទាំងលើវិស័យសង្គម/ សេដ្ឋកិច្ច | - របាយការណ៍សិក្សាស្រាវជ្រាវផលប៉ះពាល់សង្គម<br>- របាយការណ៍សិក្សាស្រាវជ្រាវសុខុមាលភាពបឹង ទន្លេសាប<br>- ក្របខណ្ឌយុទ្ធសាស្ត្រនៃការគ្រប់គ្រងតំបន់អភិរក្សព្រៃលិច ទឹកតំបន់៣ | - ទិន្នន័យផលប៉ះពាល់សង្គម (ស្ថានភាពសេដ្ឋកិច្ចសង្គម និងការពឹង ផ្អែករបស់ប្រជាជនទៅលើការប្រែប្រួលធនធានទឹក...)<br>- ទិន្នន័យពាក់ព័ន្ធនឹងអេកូស៊ីសស្តែម ជីវចម្រុះ និងភាពធន់របស់វាទៅ នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ...<br>- របាយការណ៍ទិន្នន័យដែនអភិរក្សព្រៃលិចទឹកតំបន់៣ |
| ៤. ពង្រឹងប្រសិទ្ធភាព និង ការរៀបចំគ្រប់គ្រងប្រព័ន្ធ ទិន្នន័យរបស់អាជ្ញាធរ ទន្លេសាប | - សេចក្តីសម្រេច ស្តីពី ការកែសម្រួលក្រុមការងារបច្ចេក ទេសទទួលបន្ទុក និងគ្រប់គ្រងប្រព័ន្ធទិន្នន័យ<br>- សម្ភារះបច្ចេកទេសត្រូវបានពង្រឹងពង្រីកទាំងបរិមាណ និងគុណភាព<br>- មន្ត្រីជំនាញទាំង៤រូប ត្រូវបានទទួលការបណ្តុះ បណ្តាលបន្ថែម<br>- ទិន្នន័យរបស់អាជ្ញាធរទន្លេសាបត្រូវបានប្រមូលផ្តុំ<br>- ទិន្នន័យត្រូវបានចែករំលែកដល់ភាគីពាក់ព័ន្ធ<br>- ការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យក្នុងប្រព័ន្ធបច្ចុប្បន្ន ភាព TSA-Server | - ប្រព័ន្ធចែករំលែករបស់ អ.ទ.ស ត្រូវបានប្រើប្រាស់ជាផ្លូវការក្នុងប្រព័ន្ធ អេឡិចត្រូនិច និងចែករំលែកដល់ភាគីពាក់ព័ន្ធ<br>- ក្រសួង/ស្ថាប័ន និងភាគីពាក់ព័ន្ធទទួលបានការយល់ដឹងនិងចូលរួម គាំទ្រដល់ដំណើរការងារ អ.ទ.ស<br>- របាយការណ៍ស្តីពីស្ថានភាពតំបន់បឹងទន្លេសាប ត្រូវបានអនុម័ត និង ផ្សព្វផ្សាយប្រើប្រាស់ជាផ្លូវការ និងរក្សាទុកក្នុង Server<br>-ផែនទីបច្ចុប្បន្នភាពតំបន់បឹងទន្លេសាបត្រូវបានអនុម័តនិងចែករំលែក ផ្សព្វផ្សាយប្រើប្រាស់ជាផ្លូវការ និងរក្សាទុក Server<br>- ទិន្នន័យត្រូវបានរក្សាទុក និងប្រើប្រាស់ក្នុងប្រព័ន្ធបច្ចុប្បន្នភាព TSA-Server និងប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យតំបន់បឹងទន្លេសាប |
| ៥. ពង្រឹងកិច្ចសហប្រតិបត្តិការ និងការគ្រប់គ្រងលើការចែក រំលែកព័ត៌មានវិទ្យា | - ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធមានចំនួនកើនឡើង<br>- ប្រព័ន្ធចែករំលែករបស់ អ.ទ.ស (TSA's Information Sharing System)<br>- របាយការណ៍ ស្តីពីស្ថានភាពទន្លេសាប | - ការសហការសិក្សា សន្និសីទ សិក្ខាសាលា ប្រជុំ វគ្គបណ្តុះបណ្តាល<br>- ប្រព័ន្ធបណ្តាញចែករំលែកផ្សព្វផ្សាយ អ.ទ.ស<br>- ប្រសិទ្ធភាពនៃការកើនឡើងនៃភាគីពាក់ព័ន្ធ និងដៃគូសហប្រតិបត្តិការ |

| | | |
|---|---|---|
| | - ផែនទីបច្ចុប្បន្នភាពតំបន់បឹងទន្លេសាប | - វគ្គពង្រឹងសមត្ថភាពដល់អ្នកពាក់ព័ន្ធ |
| ៦.ជំរុញប្រសិទ្ធភាពយន្តការសម្របសម្រួល និងប្រឹក្សាយោបល់ | - កិច្ចសន្ទនា និងប្រឹក្សាយោបល់ត្រូវបានពង្រីក<br>- ការលើកទឹកចិត្ត និងបង្កើនជំនឿទុកចិត្តដល់បណ្តាញទំនាក់ទំនងការងារសមាជិកអ.ទ.ស និងភាគីពាក់ព័ន្ធ។<br>- ការបង្កើតនូវប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យតំបន់បឹងទន្លេសាប | - កិច្ចសន្ទនា និងប្រឹក្សាយោបល់តាមរយៈកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល....<br>- ទស្សនាទាន និងគំនិតយោបល់ពីអ្នកពាក់ព័ន្ធចូលរួមក្នុងការចែករំលែក ការរៀបចំកសាងគោលនយោបាយផែនការយុទ្ធសាស្ត្រ<br>- ប្រព័ន្ធ TSA-Server ត្រូវបានបច្ចុប្បន្នភាពគ្រប់គ្រងនិងទំនើបកម្មផ្ទុកមូលដ្ឋានទិន្នន័យ database |
| ៧.លើកកម្ពស់ប្រសិទ្ធភាពកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ | - លើកកម្ពស់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ<br>- សកម្មភាពនៃការទំនាក់ទំនងនិងការចូលរួមរបស់អ្នកពាក់ព័ន្ធលើកិច្ចការរបស់អាជ្ញាធរទន្លេសាបក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លសាប<br>- ទស្សនៃការយល់ដឹងក្នុងការចូលរួមគាំទ្រ និងសហប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ | - ប្រសិទ្ធភាពនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ<br>- ប្រសិទ្ធភាពនៃការចូលរួមគាំទ្រ និងការអនុវត្តរបស់ភាគីពាក់ព័ន្ធ ក្នុងការអនុវត្តន៍<br>- សមត្ថភាពរបស់ អ.ទ.ស ក្នុងការសម្របសម្រួល និងការទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ |
| ៨.លើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងដំណើរការស្ថាប័នប្រកបដោយចីរភាព | - របាយការណ៍វាយតម្លៃការកសាងសមត្ថភាព<br>- ឯកសារបណ្តុះបណ្តាល និងសម្ភារក្នុងការបណ្តុះបណ្តាល<br>- វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សា<br>- សេចក្តីណែនាំ ឬគោលការណ៍បន្ថែមក្នុងការពង្រឹងការងារអាជ្ញាធរទន្លេសាប | - ផែនការ/កម្មវិធីកសាងអភិវឌ្ឍន៍សមត្ថភាព និងការយល់ដឹងត្រូវបានអនុម័ត<br>- សកម្មភាពនៃវគ្គបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង<br>- មន្ត្រី អ.ទ.ស ទទួលបានការសិក្សាបន្តថ្នាក់អនុបណ្ឌិត និងបណ្ឌិត<br>- ផែនការសកម្មភាពប្រចាំឆ្នាំត្រូវបានអនុម័ត |

| | | |
|---|---|---|
| | - ផែនការ/កម្មវិធីសកម្មភាពបណ្តុះបណ្តាល, លើកកម្ពស់ការយល់ដឹង<br>- ផែនការសកម្មភាពប្រចាំឆ្នាំ | |
| ៩. អភិវឌ្ឍន៍គោលនយោបាយយុទ្ធសាស្រ្ត និងកសាងផែនការសម្រាប់តំបន់បឹងទន្លេសាប | - ផែនការយុទ្ធសាស្រ្តសម្រាប់តំបន់បឹងទន្លេសាប<br>- គោលនយោបាយ សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍតំបន់បឹងន្លេសាប<br>- ផែនការចង្អុលបង្ហាញ/ផែនការមេសម្រាប់តំបន់បឹងទន្លេសាប | - ផែនការយុទ្ធសាស្រ្តសម្រាប់តំបន់ទន្លេសាបត្រូវបានរៀបចំ និងអនុម័តឲ្យអនុវត្តន៍ផ្លូវការនៅចន្លោះឆ្នាំ២០២៣-២០២៧<br>- គោលនយោបាយសម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍតំបន់បឹងទន្លេសាបត្រូវបានរៀបចំ និងអនុម័ត<br>- ផែនការចង្អុលបង្ហាញ/ផែនការមេសម្រាប់តំបន់ទន្លេសាបត្រូវបានរៀបចំ និងអនុម័ត |
| ១០.ពង្រឹងសមត្ថភាពមន្រ្តីលើការសិក្សាស្រាវជ្រាវតាមដានលើប្រធានបទនីមួយៗតាមគោលដៅរបស់អាជ្ញាធរទន្លេសាប | - របាយការណ៍វាយតម្លៃការកសាងសមត្ថភាពលើមេរៀន និងសម្ភារក្នុងការបណ្តុះបណ្តាល<br>- វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សា<br>- កិច្ចប្រជុំបណ្តុះបណ្តាល សកម្មភាពចុះសិក្សាស្រាវជ្រាវ និងទស្សនកិច្ចសិក្សារបស់ស្ត្រីយ៉ាងតិច ៥លើក | - ផែនការ/កម្មវិធីសកម្មភាពពង្រឹងសមត្ថភាពអនុម័តជាគោលការណ៍<br>- វគ្គបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងត្រូវបានអនុវត្ត២ ឬ៣វគ្គ/១ឆ្នាំ<br>- មន្រ្តីរាជការ និងមន្រ្តីជាប់កិច្ចសន្យា អ.ទ.ស ក្រសួង/ស្ថាប័ន និងភាគីពាក់ព័ន្ធទទួលបានការបណ្តុះបណ្តាល |

## ដ្យាក្រាមទី៤ ផែនការយុទ្ធសាស្ត្រ អ.ទ.ស ២០២១-២០២៥



# ផ្នែកទី៤

# យន្តការសម្រាប់អនុវត្ត និងប្រភពថវិកា ធនធានហិរញ្ញវត្ថុ

## ៤.១- យន្តការសម្រាប់អនុវត្ត

ផែនការយុទ្ធសាស្ត្រ៥ឆ្នាំ របស់អាជ្ញាធរទន្លេសាបនឹងត្រូវអនុវត្តបានតាមរយៈការធ្វើផែនការសកម្មភាពការងារលម្អិតប្រចាំឆ្នាំនីមួយៗ ក្រោយពីផែនការយុទ្ធសាស្ត្រ ២០២១-២០២៥ បានអនុម័ត និងដាក់ឲ្យអនុវត្តជាផ្លូវការស្របតាមផែនការថវិកាកម្មវិធីរបស់រាជរដ្ឋាភិបាល។ ផែនការថវិកាកម្មវិធីប្រចាំឆ្នាំ នឹងមានចែងលម្អិតអំពីគោលបំណងកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងតម្រូវការថវិកាដែលនឹងត្រូវពិភាក្សាជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធបន្ថែមទៀត។

អគ្គលេខាធិការដ្ឋាន គឺជាអ្នករៀបចំ អនុវត្ត គ្រប់គ្រង និងដឹកនាំលើផែនការយុទ្ធសាស្ត្រនេះ ដែលមាននាយកដ្ឋានជំនាញទាំង៤ជាអ្នកទទួលខុសត្រូវលើការអនុវត្តន៍សកម្មភាពរៀងៗខ្លួនតាមជំនាញ។ នាយកដ្ឋានទាំង៤ ត្រូវលើកសំណើដើម្បីអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំដោយផ្អែកលើសកម្មភាពយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រនេះ និងដោយអនុលោមតាមតួនាទី ភារកិច្ច របស់នាយកដ្ឋាននីមួយៗដែលមានចែងនៅក្នុងអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប។

សម្រាប់ការតាមដានវឌ្ឍនភាពនៃការអនុវត្ត នាយកដ្ឋានជំនាញទាំងអស់ត្រូវរៀបចំរបាយការណ៍វឌ្ឍនភាពរបស់ខ្លួនតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពរៀងៗខ្លួន និងបញ្ជូនមកនាយកដ្ឋាន រដ្ឋបាលផែនការ និងសហប្រតិបត្តិការ ដើម្បីធ្វើការបូកសរុប និងរៀបចំផលិតរបាយការណ៍រួម របស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប។

## ៤.២- ប្រភពថវិកា និងធនធានហិរញ្ញវត្ថុ

ការអនុវត្តផែនការយុទ្ធសាស្ត្រ៥ឆ្នាំ របស់អាជ្ញាធរទន្លេសាប ២០២១-២០២៥ ដោយប្រើប្រាស់ថវិកាជាតិ និងថវិកាពីប្រភពផ្សេងៗ។ ថវិការបស់អាជ្ញាធរទន្លេសាប ជាថវិកាកម្មវិធីប្រចាំឆ្នាំ ដែលអនុម័តដោយរាជរដ្ឋាភិបាល។ សម្រាប់តម្រូវការចំណាយក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ គឺប្រមាណ ២៦,៧០០ លានរៀល (ម្ភៃប្រាំមួយពាន់ប្រាំពីររយលានរៀលគត់) ក្នុងរយៈពេល៥ឆ្នាំ ក្នុងនោះដែរអាជ្ញាធរទន្លេសាបដើរតួនាទីសម្របសម្រួលដើម្បីទាក់ទាញ និងកៀរគរប្រភពថវិកាក្រៅពីកញ្ចប់ថវិការាជរដ្ឋាភិបាលផ្តល់ប្រចាំឆ្នាំ ដែលជាទុនបដិភាគ ឬវិភាគទានបន្ថែមបានពីវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយនានា តាមរយៈការសរសេរគម្រោងស្នើសុំ និងការសិក្សាស្រាវជ្រាវផ្សេងៗ។

សម្រាប់ឆ្នាំ២០២១ ជាឆ្នាំទី១នៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ឆ្លងតាមរយៈកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងធនធានទឹក និងឧតុនិយម កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ អាជ្ញាធរទន្លេសាបនឹងទទួលបានកញ្ចប់ថវិកាចំនួន ៤,៣០០ លានរៀល (បួនពាន់បីរយលានរៀលគត់)។ អាជ្ញាធរទន្លេសាបកំពុងសហការជាមួយគម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន

ដែលមានកញ្ចប់ថវិកាផ្ដល់ដោយទីភ្នាក់ងារអភិវឌ្ឍន៍បារាំង គម្រោង Fisher Catch Monitoring in the Provinces around Tonle Sap Lake, Cambodia ដែលទទួលកញ្ចប់ថវិកាពីគណៈកម្មការទន្លេមេគង្គ (Mekong River Commission) និងគម្រោងកិច្ចសហប្រតិបត្តិការជាមួយគម្រោង SATREPS របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)។

### តារាងម៉ាទ្រិកទី ៣ តារាងប៉ាន់ប្រមាណថវិកាសម្រាប់គោលដៅយុទ្ធសាស្ត្រ

| គោលដៅយុទ្ធសាស្ត្រ | ធនធានហិរញ្ញវត្ថុប៉ាន់ស្មានតាមឆ្នាំ (លានរៀល) | | | | | សរុប (លានរៀល) |
|---|---|---|---|---|---|---|
| | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | |
| ១)ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រជាមូលដ្ឋានក្នុងតំបន់បឹងទន្លេសាប | ២,៥៦០ | ២,៥៩០ | ២,៦១០ | ២,៦៣០ | ២,៦៦០ | ១៣,០៥០ |
| ២)ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា | ៩៦០ | ៩៨០ | ៩៩០ | ៩៩០ | ១,០១០ | ៤,៩៣០ |
| ៣)លើកកម្ពស់ប្រសិទ្ធភាពនៃការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធនៃដៃគូអភិវឌ្ឍន៍ | ៧៨០ | ៧៩០ | ៨០០ | ៨០០ | ៩០០ | ៤,០៧០ |
| ៤)ពង្រឹងការគ្រប់គ្រងអង្គភាព/ស្ថាប័ន និងមូលដ្ឋានចំណេះដឹងលើការសិក្សាស្រាវជ្រាវ | ៨៦០ | ៨៩០ | ៩២០ | ៩៤០ | ១,០៤០ | ៤,៦៥០ |
| សរុបរួម | ៥,១៦០ | ៥,២៥០ | ៥,៣២០ | ៥,៣៦០ | ៥,៦១០ | ២៦,៧០០ |
| ថវិកា អ.ទ.ស | ៤,៣០០ | - | - | - | - | |
| ថវិកាផ្សេងៗ | ៨៦០ | - | - | - | - | |

## តារាងទីម៉ាទ្រិកទី ៤ ការប៉ាន់ប្រមាណថវិកាសម្រាប់គោលដៅយុទ្ធសាស្ត្រ

| គោលដៅយុទ្ធសាស្ត្រ | ការប៉ាន់ស្មានថវិកា (គិតជា លានរៀល) | | | | | | |
|---|---|---|---|---|---|---|---|
| | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | សរុប | ភាគរយ |
| **១.ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រជាមូលដ្ឋានក្នុងតំបន់បឹងទន្លេសាប** | | | | | | | |
| ១.១.ជំរុញប្រសិទ្ធភាព និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវតាមដានលើអេកូស៊ីសស្តែមតំបន់បឹងទន្លេសាប | ១,០០០ | ៩៦០ | ៩៨០ | ៩៨០ | ៩៥០ | ៤,៨៧០ | ១៨% |
| ១.២. ពង្រឹងប្រសិទ្ធភាពនៃការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍព្រមទាំងការតាមដានត្រួតពិនិត្យសកម្មភាពដែលបាន និងកំពុងអនុវត្ត | ៦៨០ | ៧៤០ | ៨១០ | ៧០០ | ៨០០ | ៣៧៣០ | ១៤% |
| ១.៣. ពង្រឹងការតាមដានជាសកម្មលើផលប៉ះពាល់អេកូស៊ីស្តែម និងសម្របសម្រួលតាមការប្រែប្រួលអាកាសធាតុតំបន់បឹងទន្លេសាបទាំងលើធនធានធម្មជាតិ ទាំងលើសេដ្ឋកិច្ច/សង្គម | ៨៨០ | ៨៩០ | ៨២០ | ៩៥០ | ៩១០ | ៤,៤៥០ | ១៧% |
| **២. ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា** | | | | | | | |
| ២.១. ពង្រឹងប្រសិទ្ធភាព និងការរៀបចំគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់អាជ្ញាធរទន្លេសាប | ៥០០ | ៥១០ | ៤៩០ | ៤៩០ | ៥០០ | ២,៤៩០ | ៩% |
| ២.២. ពង្រឹងកិច្ចសហប្រតិបត្តិការ និងការគ្រប់គ្រងលើការចែករំលែកព័ត៌មានវិទ្យា | ៤៦០ | ៤៧០ | ៥០០ | ៥០០ | ៥១០ | ២,៤៤០ | ៩% |
| **៣. លើកកម្ពស់ប្រសិទ្ធភាពនៃការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍** | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣.១.ជំរុញប្រសិទ្ធភាពយន្តការសម្របសម្រួល និងប្រឹក្សាយោបល់ | ៤៤០ | ៤៥០ | ៥០០ | ៥០០ | ៥០០ | ២,៣៩០ | ៩% |
| ៣.២.លើកកម្ពស់ប្រសិទ្ធភាពកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ | ៣៤០ | ៣៤០ | ៣០០ | ៣០០ | ៤០០ | ១,៦៨០ | ៦% |
| **៤. ពង្រឹងការគ្រប់គ្រងអង្គភាព/ស្ថាប័ន និងមូលដ្ឋានចំណេះដឹងលើការសិក្សាស្រាវជ្រាវ** | | | | | | | |
| ៤.១.លើកកម្ពស់ប្រសិទ្ធភាពក្នុងកាគ្រប់គ្រង និងដំណើការស្ថាប័នប្រកបដោយចីរភាព | ៣០០ | ៣១០ | ៣២០ | ៣២៥ | ៣៥០ | ១,៦០៥ | ៦% |
| ៤.២. អភិវឌ្ឍន៍គោលនយោបាយយុទ្ធសាស្ត្រ និងកសាងផែនការសម្រាប់តំបន់បឹងទន្លេសាប | ២៦០ | ៣០០ | ៣១០ | ៣១៥ | ៤១០ | ១,៥៩៥ | ៦% |
| ៤.៣. ពង្រឹងសមត្ថភាពមន្ត្រីលើការសិក្សាស្រាវជ្រាវតាមដានលើប្រធានបទនីមួយៗ តាមគោលដៅរបស់អាជ្ញាធរទន្លេសាប | ៣០០ | ២៨០ | ២៩០ | ៣០០ | ២៨០ | ១,៤៥០ | ៥% |
| សរុប | ៥,១៦០ | ៥,២៥០ | ៥,៣២០ | ៥,៣៦០ | ៥,៦១០ | ២៦,៧០០ | ១០០% |
| ថវិកា អ.ទ.ស | ៤,៣០០ | - | - | - | - | - | |
| ថវិកាផ្សេងៗ | ៨៦០ | - | - | - | - | - | |

# ផ្នែកទី៥
# ការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងសេចក្តីសន្និដ្ឋាន

## ៥.១- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រនេះឲ្យកាន់តែមានប្រសិទ្ធភាព អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាបនឹងប្រើប្រាស់យន្តការចំនួន៣ រួមមាន៖

១) ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ

២) ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការពាក់កណ្តាលអាណត្តិ(២ឆ្នាំកន្លះ)

៣) ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ។

ការិយាល័យផែនការ និងសហប្រតិបត្តិការ នៃនាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការជាសេនាធិការរបស់អគ្គលេខាធិការដ្ឋានក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។

### ៥.១.១. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ

អគ្គលេខាធិការដ្ឋាន នឹងចងក្រងផែនការសកម្មភាពប្រចាំឆ្នាំរៀងរាល់ឆ្នាំ។ ការិយាល័យផែនការ និងសហប្រតិបត្តិការ នៃនាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ ជាអង្គភាពប្រមូលផ្តុំផែនការសកម្មភាពគ្រប់នាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋានទាំងអស់ ដើម្បីរៀបចំចងក្រងបោះពុម្ពជាផែនការសកម្មភាពការងារប្រចាំឆ្នាំរួមរបស់អាជ្ញាធរទន្លេសាបឲ្យបាននៅដើមត្រីមាសទី១ ជារៀងរាល់ឆ្នាំ។ ការតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការនឹងត្រូវធ្វើឡើងតាមរយៈការពិនិត្យ និងវាយតម្លៃលើរបាយការណ៍សមិទ្ធផលប្រចាំឆ្នាំ។

### ៥.១.២. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការពាក់កណ្តាលអាណត្តិ

ការវាយតម្លៃពាក់កណ្តាលអាណត្តិ សម្រាប់ផែនការនេះ នឹងត្រូវចាប់ផ្តើមធ្វើឡើងនៅដើមឆ្នាំ២០២៣ ដើម្បីពិនិត្យលើវឌ្ឍនភាពការងារក៏ដូចជាសិក្សាអំពីបញ្ហាប្រឈមដែលជួបប្រទះក្នុងអំឡុងពេលអនុវត្តន៍ផែនការយុទ្ធសាស្ត្រ។ របាយការណ៍សមិទ្ធផលប្រចាំឆ្នាំទី១ ទី២ និងឆមាសទី១ នៃឆ្នាំទី៣ នឹងត្រូវប្រើប្រាស់ដើម្បីពិនិត្យ និងវាយតម្លៃការអនុវត្តពាក់កណ្តាលអាណត្តិនៃផែនការនេះ។ម្យ៉ាងវិញទៀត របាយការណ៍សមិទ្ធផលដែលសម្រេចបាននៅពាក់កណ្តាលអាណត្តិនៃផែនការនេះ ក៏ត្រូវប្រើប្រាស់ដើម្បីធៀបនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្នុងការឆ្លុះបញ្ចាំងពីការរួមចំណែករបស់អាជ្ញាធរទន្លេសាបទៅលើផែនការយុទ្ធសាស្ត្រនេះ។

របាយការណ៍សមិទ្ធផល និងលទ្ធផលនៃការធៀបនេះនឹងត្រូវបានប្រើប្រាស់ក្នុងការពិនិត្យលទ្ធភាពក្នុងការស្វែងរកបទអន្តរាគមន៍ផ្សេងៗ ដើម្បីកែលំអ និងលើកទិសដៅបន្តសម្រាប់ការអនុ

វត្តផែនការពាក់កណ្តាលអាណត្តិបន្ត និងប្រមូលបទពិសោធន៍នានាសម្រាប់ជួយគាំទ្រដល់នាយកដ្ឋានជំនាញដែលជាប្រតិបត្តិករក្នុងការអនុវត្តផែនការឲ្យកាន់តែមានប្រសិទ្ធភាព។

### ៥.១.៣. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ

នៅត្រីមាសទី៣ នៃឆ្នាំ២០២៥ ដំណើរការពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រនេះនឹងត្រូវចាប់ផ្តើម។ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ និងលទ្ធផលនៃការត្រួតពិនិត្យ និងវាយតម្លៃលើពាក់កណ្តាលអាណត្តិ(២ឆ្នាំកន្លះ) នឹងត្រូវបានប្រើប្រាស់ជាឯកសារមូលដ្ឋានក្នុងការវាយតម្លៃលើការអនុវត្តផែនការទាំងមូលចន្លោះពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥។ សមិទ្ធផលនៃការអនុវត្តរយៈពេល ៥ឆ្នាំ ដែលទទួលបានពីការអនុវត្តផែនការយុទ្ធសាស្ត្រនេះ នឹងត្រូវយកទៅធៀបជាមួយនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលដើម្បីឆ្លុះបញ្ចាំងពីការចូលរួមចំណែករបស់អាជ្ញាធរទន្លេសាបចំពោះសមិទ្ធផលរួមនៃយុទ្ធសាស្ត្រនេះ។

រាល់សមិទ្ធផល និងបញ្ហាប្រឈមទាំងឡាយនៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះនឹងត្រូវបានប្រើប្រាស់ជាមូលដ្ឋានដើម្បីរៀបចំជាទិសដៅយុទ្ធសាស្ត្រសម្រាប់ផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាបជាបន្តបន្ទាប់។

## ៥.២- សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រនេះ គឺជាផែនទីបង្ហាញផ្លូវដ៏សំខាន់របស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប ដើម្បីអនុវត្តន៍បេសកកម្មរបស់ខ្លួនក្នុងការឈានទៅរួមចំណែកសម្រេចឲ្យបាននូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជា។ ផែនការយុទ្ធសាស្ត្រនេះបានកំណត់គោលដៅ និងគោលបំណងដែលមានការផ្សារភ្ជាប់ជាមួយកម្មវិធីគោលនយោបាយនានាដែលមានស្រាប់ ដូចជាកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ និងគោលនយោបាយផ្សេងៗរបស់ក្រសួងធនធានទឹក និងឧតុនិយម។ ម្យ៉ាងទៀតផែនការយុទ្ធសាស្ត្រនេះ ក៏បានបន្សីជាមួយផែនការយុទ្ធសាស្ត្រថវិកាកម្មវិធីផងដែរ ដូចនេះហើយការកំណត់គោលបំណង កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពគឺវាមានលក្ខណៈស្របគ្នារវាងផែនការយុទ្ធសាស្ត្រទាំងពីរនេះ។

ផ្តោតលើគោលដៅយុទ្ធសាស្ត្រអាទិភាពចំនួន៤គឺ ១) ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រជាមូលដ្ឋានក្នុងតំបន់បឹងទន្លេសាប ២) ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា ៣) លើកកម្ពស់ប្រសិទ្ធភាពនៃការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ៤) ពង្រឹងការគ្រប់គ្រងអង្គភាព/ស្ថាប័ន និងមូលដ្ឋានចំណេះដឹងលើការសិក្សាស្រាវជ្រាវ។ តាមរយៈយុទ្ធសាស្ត្រដែលបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រនេះ និងការអនុវត្តគោលដៅយុទ្ធសាស្ត្រ

ទាំង៣ខាងលើនេះ អាជ្ញាធរទន្លេសាបរំពឹងនឹងសម្រេចសមិទ្ធផលថ្មីៗផ្សេងទៀតជាច្រើនទៀត ជូនរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសពាក់ព័ន្ធនឹងការងារដូចខាងក្រោមៈ

១) ធ្វើឲ្យមន្ត្រីរាជការមានភាពសកម្ម និងទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន

២) ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យកាន់តែមានប្រសិទ្ធភាព

៣) ភាគីពាក់ព័ន្ធកាន់តែចាប់អារម្មណ៍ដើម្បីចូលរួមសហការ បង្កើតភាពជាដៃគូរ និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិនានាក្នុងតំបន់។

អាជ្ញាធរទន្លេសាបសង្ឃឹមថា ភាគីពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា នឹងចូលរួមសហការអនុវត្ត និងតាមដានលើការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ឲ្យបានជោគជ័យតាមលទ្ធផលដែលបានគ្រោងទុក។ ហើយក៏រំពឹងផងដែរថា ផែនការយុទ្ធសាស្ត្រនេះនឹងរួមចំណែកគាំទ្រដល់ការសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ សំដៅធ្វើឲ្យកម្ពុជាបានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

## ឧបសម្ព័ន្ធទី១ ព្រះរាជក្រឹត្យលេខ នស/រកត/ ០៦០៩/៧០៥ ស្តីពី ការបង្កើតអាជ្ញាធរទន្លេសាប

នស/រកត/០៦០៩/៧០៥

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការបង្កើតអាជ្ញាធរទន្លេសាប

### យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- ១ -

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងវបនីយជីវមណ្ឌលបឹងទន្លេសាប
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតអាជ្ញាធរមួយ សម្រាប់សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប មានឈ្មោះថា **អាជ្ញាធរទន្លេសាប** ដែលហៅជាអក្សរកាត់ថា **អ.ទ.ស.** ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់រាជរដ្ឋាភិបាល ។

**មាត្រា ២.-**

វិសាលភាពនៃតំបន់ទន្លេសាប ត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- ២ -

## ជំពូកទី ២

## សមាសភាព

**មាត្រា ៣.-**

**អ.ទ.ស.** មានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| - ឧបនាយករដ្ឋមន្ត្រី ឬ ទេសរដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រី | | ប្រធាន |
| - ឥស្សរជនជាន់ខ្ពស់មួយចំនួន | | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងបរិស្ថាន | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងផែនការ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកិច្ចការនារី | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១រូប | សមាជិក |
| - អនុប្រធាន ឬអគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ០១រូប | សមាជិក |
| - ប្រធាន ឬអនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | ០១រូប | សមាជិក |
| - ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | | សមាជិក |
| - អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | | សមាជិក |
| - អគ្គលេខាធិការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | | សមាជិក |
| - អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា | | សមាជិក |

- ៣ -

- អគ្គនាយកអាជ្ញាធរអប្សរា សមាជិក
- អភិបាលខេត្តកំពង់ឆ្នាំង សមាជិក
- អភិបាលខេត្តពោធិ៍សាត់ សមាជិក
- អភិបាលខេត្តបាត់ដំបង សមាជិក
- អភិបាលខេត្តបន្ទាយមានជ័យ សមាជិក
- អភិបាលខេត្តសៀមរាប សមាជិក
- អភិបាលខេត្តកំពង់ធំ សមាជិក
- អភិបាលខេត្តកំពង់ចាម សមាជិក
- អភិបាលខេត្តកណ្ដាល សមាជិក។

សមាសភាពជាក់ស្ដែងរបស់ **អ.ទ.ស.** ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី ៣
## ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ អ.ទ.ស.

**មាត្រា ៤.-**

**អ.ទ.ស.** មានតួនាទី ភារកិច្ច សម្រាប់សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប ដូចតទៅ៖

- ជាសេនាធិការផ្ទាល់ឱ្យរាជរដ្ឋាភិបាលលើរាល់គម្រោង ដោយធ្វើការសិក្សាស្រាវជ្រាវ ត្រួតពិនិត្យ និងផ្ដល់អនុសាសន៍ជូនរាជរដ្ឋាភិបាល
- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធី និងគម្រោងផ្សេងៗ
- សម្របសម្រួលរាល់សកម្មភាព ដែលកំពុងអនុវត្ត គ្រោងនឹងអនុវត្ត របស់ក្រសួងស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា ដែលមាននៅក្នុងតំបន់ទន្លេសាប ដើម្បីឱ្យការងារមានភាពរលូនជាមួយគ្នាប្រកបដោយប្រសិទ្ធភាព
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងនានា ដើម្បីជំរុញឱ្យប្រតិបត្តិករពាក់ព័ន្ធអនុវត្តស្របតាមយុទ្ធសាស្ត្រ និងផែនការរបស់រាជរដ្ឋាភិបាល
- ធ្វើជាតំណាងរាជរដ្ឋាភិបាលក្នុងសកម្មភាពការងាររួមមាន កិច្ចប្រជុំ ការចរចា និងការដោះស្រាយរាល់បញ្ហាដែលអាចកើតមានជាយថាហេតុ
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ កិច្ចសន្យាទាំងឡាយ ក្រោយពីមានការឯកភាពពីរាជរដ្ឋាភិបាល

- ៤ -

- ជាសមភាគីជាមួយគ្រប់ដៃគូអភិវឌ្ឍទាំងអស់ក្នុងការរួមគ្នាពិចារណា ដើម្បីកំណត់សកម្មភាពដែលត្រូវអនុវត្ត
- ប្រមូល វិភាគ និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ទិន្នន័យ ដើម្បីផ្សព្វផ្សាយ និងចែករំលែកដល់អ្នកពាក់ព័ន្ធ
- អប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងដល់អ្នកពាក់ព័ន្ធ
- រាយការណ៍ជូនរាជរដ្ឋាភិបាលអំពីសកម្មភាពការងារសំខាន់ៗ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

**មាត្រា ៥.-**

**អ.ទ.ស.** មានគណៈកម្មាធិការប្រតិបត្តិមួយ សម្រាប់ដឹកនាំការងារប្រចាំថ្ងៃ ដោយមានការណែនាំ និងចង្អុលទិសពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាព ដូចតទៅ៖

| | |
|---|---|
| - ប្រធាន អ.ទ.ស. | ប្រធាន |
| - អនុប្រធាន អ.ទ.ស. | អនុប្រធាន |
| - អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ទ.ស. | សមាជិក |
| - អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន អ.ទ.ស. | សមាជិក ។ |

**មាត្រា ៦.-**

**អ.ទ.ស.** ដឹកនាំដោយប្រធានមួយរូប មានឋានៈទាបបំផុតស្មើរដ្ឋមន្ត្រីជាអ្នកទទួលខុសត្រូវរួមចំពោះមុខរាជរដ្ឋាភិបាល អមដោយអនុប្រធាន និងទីប្រឹក្សាមួយចំនួនជាជំនួយការ ។

**មាត្រា ៧.-**

**អ.ទ.ស.** មានអគ្គលេខាធិការដ្ឋានមួយ សម្រាប់ដំណើរការការងារប្រចាំថ្ងៃ និងចាត់ការទូទៅលើការងារសម្របសម្រួល ទំនាក់ទំនង និងសហការរវាង ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា សម្រាប់គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាបប្រកបដោយនិរន្តរភាព ។

អគ្គលេខាធិការដ្ឋាន **អ.ទ.ស.** ដឹកនាំដោយអគ្គលេខាធិការមួយរូប មានឋានៈស្មើរដ្ឋលេខាធិការអមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ ។

អគ្គលេខាធិការដ្ឋានត្រូវអនុវត្តការងារទៅតាមការណែនាំរបស់ប្រធាន ។

**មាត្រា ៨.-**

ដើម្បីបំពេញការងាររបស់ខ្លួន ជូនរាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពខ្ពស់ **អ.ទ.ស.** ត្រូវមានតំណាងចូលរួម[illegible]ដាន និងផ្តល់យោបល់នៅក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងអង្គប្រជុំអន្តរក្រសួងផ្សេងៗ ពាក់ព័ន្ធនឹងក្នុងការងារទន្លេសាបដែលរៀបចំដោយទីស្តីការគណៈរដ្ឋមន្ត្រី ឬដោយក្រសួង ស្ថាប័ននានា ។

- ៥ -

**អ.ទ.ស.** មានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់នៃក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធនានា ឬឥស្សរជនដែលមានបទពិសោធ និងសមត្ថភាពខ្ពស់ ដើម្បីចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ខ្លួន។

ក្នុងរយៈពេល ៣ (បី) ខែ **អ.ទ.ស.** ត្រូវកោះប្រជុំសាមញ្ញម្តង។ ក្នុងករណីចាំបាច់ ប្រធាន **អ.ទ.ស.** ឬគណៈកម្មាធិការប្រតិបត្តិនៃ **អ.ទ.ស.** អាចកោះប្រជុំវិសាមញ្ញ។ ករណីប្រធានអវត្តមាន អនុប្រធានមានសិទ្ធិពេញលេញក្នុងការដឹកនាំកិច្ចប្រជុំតាមការណែនាំរបស់ប្រធាន។

ក្នុងរយៈពេល ១ (មួយ) ខែ គណៈកម្មាធិការប្រតិបត្តិនៃ **អ.ទ.ស.** ត្រូវប្រជុំសាមញ្ញម្តង។

**មាត្រា ៩.-**

ការតែងតាំងមន្ត្រីរាជការ ការរៀបចំប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន **អ.ទ.ស.** ជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ១០.-**

**អ.ទ.ស.** មានសិទ្ធិប្រើត្រាដោយឡែក និងមានទីស្នាក់ការកំណត់ដោយទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ១១.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ទ.ស.** ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី ៤

## ប្រភពធនធានថវិកា

**មាត្រា ១២.-**

ប្រភពធនធានថវិការបស់ **អ.ទ.ស.** សម្រាប់បំពេញការងាររបស់ខ្លួន បានមកពី ៖

- ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- អំណោយ និងវិភាគទានពីដៃគូអភិវឌ្ឍ សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា
- ជំនួយឥតសំណង ឬកម្ចីដែលធ្វើឡើងតាមការយល់ព្រមពីរាជរដ្ឋាភិបាល។

**អ.ទ.ស.** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀត ពីប្រភពក្នុង ឬក្រៅប្រទេស សម្រាប់បម្រើសេចក្តីត្រូវការ ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាព។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

- ៦ -

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-**

ព្រះរាជក្រឹត្យនេះជំនួសព្រះរាជក្រឹត្យលេខ នស/រកត/០៩០៧/៤១២ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការបង្កើតអាជ្ញាធរអាងទន្លេសាប ដែលត្រូវបាននិរាករណ៍។

**មាត្រា ១៤.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រល.០៩០៦.៧១៤ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៦៤០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

- ៧ -

## ឧបសម្ព័ន្ធ២ ព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ស្តីពី ការកែសម្រួល មាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ស្តីពី ការបង្កើតអាជ្ញាធរទន្លេសាប

**ព្រះរាជក្រឹត្យ**

នស/រកត/០៣១០/២៥៨

**ស្តីពី**

**ការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

ROYAUME DU CAMBODGE ROYAL * MINISTRE DU PALAIS ROYAL

១

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងបំរុងជីវមណ្ឌលបឹងទន្លេសាប

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ.-**

ត្រូវបានកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប ដូចតទៅ ៖

**មាត្រា៣ថ្មី.-**

**អ.ទ.ស.** មានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| -ឧបនាយករដ្ឋមន្ត្រី ឬ ទេសរដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រី | | ប្រធាន |
| -ឥស្សរជនជាន់ខ្ពស់មួយចំនួន | | អនុប្រធាន |
| -ឥស្សរជនជាន់ខ្ពស់ | ០១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងបរិស្ថាន | ០១រូប | សមាជិក |

២

| | | |
|---|---|---|
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងផែនការ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកិច្ចការនារី | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១រូប | សមាជិក |
| -រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | សមាជិក |
| -អនុប្រធាន ឬអគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ០១រូប | សមាជិក |
| -ប្រធាន ឬអនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | ០១រូប | សមាជិក |
| -តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | | សមាជិក |
| -អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | | សមាជិក |
| -អគ្គលេខាធិការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | | សមាជិក |
| -អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា | | សមាជិក |
| -អគ្គនាយកអាជ្ញាធរអប្សរា | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តកណ្តាល | | សមាជិក |

សមាសភាពជាក់ស្តែងរបស់ **អ.ទ.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

៣

**មាត្រា៥ថ្មី.-**

**អ.ទ.ស.** មានគណៈកម្មាធិការប្រតិបត្តិមួយ សម្រាប់ដឹកនាំការងារប្រចាំថ្ងៃ ដែលមានសមាសភាពដូចតទៅ ៖

| | |
|---|---|
| -ប្រធាន អ.ទ.ស. | ប្រធាន |
| -អនុប្រធាន និងអនុប្រធានអចិន្ត្រៃយ៍ អ.ទ.ស. | អនុប្រធាន |
| -អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ទ.ស. | សមាជិក |
| -អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន អ.ទ.ស. | សមាជិក។ |

**មាត្រា៦ថ្មី.-**

**អ.ទ.ស.** ដឹកនាំដោយប្រធានមួយរូប ជាអ្នកទទួលខុសត្រូវរួមចំពោះមុខរាជរដ្ឋាភិបាល អមដោយអនុប្រធាន និងអនុប្រធានអចិន្ត្រៃយ៍ ព្រមទាំងទីប្រឹក្សាមួយចំនួនជាជំនួយការ។

**មាត្រា៩ថ្មី.-**

ការតែងតាំងមន្ត្រីរាជការ ការរៀបចំប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន **អ.ទ.ស.** ជាបន្ទុករបស់ក្រសួងធនធានទឹក និងឧតុនិយម។

**មាត្រា១០ថ្មី.-**

**អ.ទ.ស.** មានសិទ្ធិប្រើត្រាដោយឡែករបស់ខ្លួន។

**មាត្រា១២ថ្មី.-**

ប្រភពធនធានថវិការបស់ **អ.ទ.ស.** សម្រាប់បំពេញការងាររបស់ខ្លួន បានមកពី ៖

-ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំ របស់ក្រសួងធនធានទឹក និងឧតុនិយម

-អំណោយ និងវិភាគទានពីដៃគូអភិវឌ្ឍ សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា

-ជំនួយឥតសំណង ឬកម្ចីដែលធ្វើឡើងតាមការយល់ព្រមពីរាជរដ្ឋាភិបាល។

**អ.ទ.ស.**មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិ ជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀត ពីប្រភពក្នុង ឬក្រៅប្រទេស សម្រាប់បម្រើសេចក្តីត្រូវការក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាព។

៤

មាត្រា៣:..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤:..**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១០

**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់**

៣/ល.១០០៣.២៦១

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**លេខ:៧៥៧ ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ.ថ្ងៃទី៣១ ខែ មីនា ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**យុន ឋិនកេន**

៥

5/5

## ឧបសម្ព័ន្ធ៣ អនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គលេខាធិការនៃអាជ្ញាធរទន្លេសាប

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៦ អនក្រ.បក

### អនុក្រឹត្យ
### ស្តីពី
### ការរៀបចំ និងការប្រព្រឹត្តទៅ
### របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៦០៩ / ៧០៥ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរទន្លេសាប

### សម្រេច

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ( **អ.ទ.ស** ) ។

## ជំពូកទី ២
## តួនាទី និង ភារកិច្ច

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ( **អ.ទ.ស** ) មានតួនាទី និង ភារកិច្ច ដូចតទៅ :

- ទទួលបន្ទុកដឹកនាំ ចាត់ចែង និងសម្របសម្រួល រាល់សកម្មភាពការងារ ប្រចាំថ្ងៃរបស់ **អ.ទ.ស**
- សិក្សាស្រាវជ្រាវ អំពីសក្តានុពលធនធានធម្មជាតិ ដែលមានក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវ ត្រួតពិនិត្យ វាយតម្លៃ និងតាមដាន លើការធ្វើអាជីវកម្ម និងការប្រើប្រាស់ធនធានធម្មជាតិ ដែលមានក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ប្រមូលទិន្នន័យ និងធ្វើវិភាគនូវរាល់ព័ត៌មាន និងសកម្មភាពជាក់ស្តែង ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ ចំពោះមុខ និងយូរអង្វែង ជូនរាជរដ្ឋាភិបាល ក្នុងការកំណត់ទីតាំងគោលដៅបម្រើដល់កិច្ចអភិវឌ្ឍន៍ និងអភិរក្ស
- រៀបចំគោលនយោបាយ ទស្សនវិស័យ បេសកកម្មរបស់អាជ្ញាធរទន្លេសាប
- សម្របសម្រួល និងសហការ ជាមួយបណ្តាក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា លើរាល់សកម្មភាពទាក់ទងនឹងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ ក្នុងតំបន់ទន្លេសាបប្រកបដោយនិរន្តរភាព
- សហការ ជាមួយបណ្តាក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីគម្រោងអភិរក្ស អភិវឌ្ឍន៍ផ្សេងៗ ដែលមាននៅក្នុងតំបន់ទន្លេសាប
- រៀបចំចងក្រងឯកសារទិន្នន័យ ព័ត៌មាន ដើម្បីអប់រំផ្សព្វផ្សាយ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនប្រធាន **អ.ទ.ស**
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធាន **អ.ទ.ស** ប្រគល់ជូន ។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ និង ការគ្រប់គ្រង

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ( **អ.ទ.ស** ) មានរចនាសម្ព័ន្ធ ដូចខាងក្រោម :

១- នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ

២- នាយកដ្ឋានធនធានធម្មជាតិ

៣- នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស

៤- នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ។

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

**មាត្រា ៤.-**

នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តការ មានតួនាទី និងភារកិច្ច ដូចតទៅ :

- ទទួលខុសត្រូវលើសេវាកម្មរដ្ឋបាលទូទៅ និងសម្របសម្រួលការងាររដ្ឋបាល ជូនគ្រប់អង្គភាពនៅក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃ **អ.ទ.ស**
- ទទួលខុសត្រូវលើការងារសំណុំលិខិត ឯកសារ លិខិតបទដ្ឋានគតិយុត្តិ ឯកសារសម្ងាត់ ការងារតម្កល់ឯកសារ ពិធីការ សណ្តាប់ធ្នាប់ និងអនាម័យ
- គ្រប់គ្រងឯកសារ និងក្របខ័ណ្ឌមន្ត្រីរាជការ បុគ្គលិក និងរៀបចំបៀវត្ស ប្រាក់ឧបត្ថម្ភផ្សេងៗ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភ័ណ្ឌ របស់ **អ.ទ.ស**
- រៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្ស
- រៀបចំគម្រោងផែនការថវិកា សម្ភារៈ និងមធ្យោបាយនានា របស់ **អ.ទ.ស**
- រៀបចំគោលនយោបាយយុទ្ធសាស្ត្រ កម្មវិធី និងផែនការសកម្មភាព រយៈពេលខ្លី មធ្យម និងវែង សម្រាប់បម្រើដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ប្រកបដោយនិរន្តរភាព
- តាមដាន វាយតម្លៃ ប្រសិទ្ធិភាពនៃការអនុវត្តផែនការសកម្មភាព
- សម្របសម្រួល សហការ ជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- ធ្វើកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកជំនួយ
- រៀបចំកិច្ចប្រជុំ ធ្វើរបាយការណ៍ កំណត់ហេតុ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **អ.ទ.ស** ប្រគល់ជូន ។

**មាត្រា ៥.-**

នាយកដ្ឋានធនធានធម្មជាតិ មានតួនាទី និងភារកិច្ច ដូចតទៅ :

- សិក្សាស្រាវជ្រាវពីសក្តានុពលទឹក និងការប្រែប្រួលអាកាសធាតុ ព្រមទាំងកត្តាផ្សេងៗទៀត ដែលនាំឱ្យប៉ះពាល់ដល់ធនធានធម្មជាតិ ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវពីធនធានមច្ឆជាតិ ធនធានព្រៃលិចទឹក ធនធានរ៉ែ និងធនធានជីវចម្រុះផ្សេងៗទៀត ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវពីសក្តានុពលទឹក-ដី ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ពិនិត្យ និងផ្តល់យោបល់ លើការស្នើសុំប្រើប្រាស់នូវរាល់ធនធានធម្មជាតិ ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **អ.ទ.ស** ប្រគល់ជូន ។

**មាត្រា ៦.-**

នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស មានតួនាទី និងភារកិច្ច ដូចតទៅ :

- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់ លើការធ្វើអាជីវកម្មធនធានទឹក-ដី ធនធានមច្ឆជាតិ ធនធានរ៉ែ ធនធានជីវចម្រុះផ្សេងៗទៀត ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់ លើការប្រើប្រាស់រាល់ធនធានធម្មជាតិ ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ប្រមូលទិន្នន័យ ព័ត៌មាន វិភាគ ដើម្បីកំណត់តំបន់អភិរក្សធនធានទឹក ធនធានព្រៃលិចទឹក ធនធានមច្ឆជាតិ ធនធានរ៉ែ និងធនធានជីវចម្រុះផ្សេងៗទៀត ដើម្បីបញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំផែនទី សម្រាប់បម្រើដល់ការគ្រប់គ្រង ការអភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **អ.ទ.ស** ប្រគល់ជូន ។

**មាត្រា ៧.-**

នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ មានតួនាទី និងភារកិច្ច ដូចតទៅ :

- ប្រមូលចងក្រង និងសិក្សាស្វែងយល់នូវរាល់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា ដែលមានការពាក់ព័ន្ធ
- ទទួលពាក្យបណ្តឹង និងសម្រុះសម្រួលនូវរាល់វិវាទនានា ដែលកើតមានឡើងក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ចូលរួមផ្តល់យោបល់ លើការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ ដែលមានការពាក់ព័ន្ធ
- រៀបចំពិធីសារ អនុស្សរណៈ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ
- ផ្សព្វផ្សាយព័ត៌មាន ទាំងវិជ្ជមាន ទាំងអវិជ្ជមាន សំដៅបម្រើឱ្យកិច្ចអភិរក្ស និងអភិវឌ្ឍន៍ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព
- សហការ ជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **អ.ទ.ស** ប្រគល់ជូន ។

**មាត្រា ៨.-**

អគ្គលេខាធិការដ្ឋាន នៃ **អ.ទ.ស** មានមន្ត្រីបម្រើការងារ មកពីក្របខ័ណ្ឌមុខងារសាធារណៈ ។ ក្នុងករណីចាំបាច់អគ្គលេខាធិការដ្ឋាន នៃ **អ.ទ.ស** អាចមានអ្នកជំនាញការ ឬបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងាររបស់ខ្លួន ។

ការបែងចែកលំអិត អំពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីរាជការ និងបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន នៃ **អ.ទ.ស** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **អ.ទ.ស** ។

**មាត្រា ៩.-**

ការរៀបចំ និងការប្រព្រឹត្តទៅ របស់បណ្តានាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន នៃ **អ.ទ.ស** ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន **អ.ទ.ស** ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរទន្លេសាប រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ៤ ប្រកាសលេខ ០២៥ អទស ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅរបស់ការិយាល័យចំណុះបណ្តានាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរទន្លេសាប**

លេខ :....០២៥....អទស

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០០៩

**ប្រកាស**

**ស្តីពី**

**ការរៀបចំ និងការប្រព្រឹត្តិទៅ របស់ការិយាល័យចំណុះបណ្តានាយកដ្ឋាន**
**ក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប**

**ប្រធានអាជ្ញាធរទន្លេសាប**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញសេចក្តីសម្រេចលេខ ៤១ សសរ ចុះថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល ស្តីពី ការតែងតាំងសមាសភាពរបស់អាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប
- យោងតាមការចាំបាច់របស់អាជ្ញាធរទន្លេសាប

**ស ម្រេ ច**

**ប្រការ ១.-**

ត្រូវបានកំណត់អំពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់បណ្តានាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប រួមមាន :

- នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ
- នាយកដ្ឋានធនធានធម្មជាតិ
- នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស
- នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ។

១

អគារលេខ: ៣៦៤.មហាវិថី ព្រះមុនីវង្ស.សង្កាត់ ផ្សារដើមថ្កូវ.ខណ្ឌ ចំការមន.រាជធានីភ្នំពេញ. ទូរស័ព្ទ /ទូរសារលេខ: ០២៣ ៧២៧ ៤៥៤.

**ប្រការ ២.-**

នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ មានរចនាសម្ព័ន្ធ ដូចខាងក្រោម :

ក- ការិយាល័យរដ្ឋបាល

ខ- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ

គ- ការិយាល័យផែនការ និងសហប្រតិបត្តិការ

ឃ- ការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**ក-ការិយាល័យរដ្ឋបាល** មានភារកិច្ច :

- ផ្តល់សេវាកម្មរដ្ឋបាល និងសម្របសម្រួលការងាររដ្ឋបាលក្នុងអគ្គលេខាធិការដ្ឋាននៃ អ.ទ.ស
- រៀបចំតាក់តែងលិខិតរដ្ឋបាល ទទួលចុះលេខលិខិតចេញ-ចូល និងបែងចែកឯកសារ
- គ្រប់គ្រងរាល់សំណុំលិខិត ឯកសារ លិខិតបទដ្ឋានគតិយុត្តិ និងឯកសារសម្ងាត់នានា
- សម្របសម្រួលរៀបចំចាត់ចែងកិច្ចប្រជុំនានារបស់ អ.ទ.ស
- គ្រប់គ្រងបណ្តាញទំនាក់ទំនង ទឹក-ភ្លើង សណ្តាប់ធ្នាប់ និងអនាម័យក្នុងអគ្គលេខាធិការដ្ឋាននៃ អ.ទ.ស
- រៀបចំរបាយការណ៍បូកសរុបសកម្មភាពការងាររបស់នាយកដ្ឋាន
- បំពេញការងារចាំបាច់តាមការណែនាំពីប្រធាននាយកដ្ឋាន ឬអគ្គលេខាធិការ អ.ទ.ស
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស។

**ខ- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ** មានភារកិច្ច :

- រៀបចំគម្រោងផែនការថវិកា សម្ភារៈ និងមធ្យោបាយនានារបស់ អ.ទ.ស
- គ្រប់គ្រង និងរៀបចំបញ្ជីចំណូល និងចំណាយ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភ័ណ្ឌ
- រៀបចំឯកសារលទ្ធកម្ម និងផ្គត់ផ្គង់សម្ភារៈការិយាល័យ និងបរិក្ខាចាំបាច់សម្រាប់ដំណើរការការងារក្នុង អ.ទ.ស
- រៀបចំ និងដោះស្រាយប្រាក់បេសកកម្មសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រី អ.ទ.ស
- ទទួលខុសត្រូវចំពោះមុខប្រធាននាយកដ្ឋានលើរាល់បែបបទប្រើប្រាស់ថវិកា
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស។

២

**គ- ការិយាល័យផែនការ និងសហប្រតិបត្តិការ** មានភារកិច្ច :

- សិក្សា និងប្រមូលចងក្រងឯកសារគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធ
- ប្រមូល និងចងក្រងគម្រោងអភិវឌ្ឍន៍នានាដែលបានបញ្ចប់ និងកំពុងដំណើការ ព្រមទាំងគម្រោងជាប់កិច្ចសន្យា ក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងផែនការសកម្មភាព រយៈពេលខ្លី មធ្យម និងវែង សម្រាប់បម្រើដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ប្រកបដោយនិរន្តរភាព
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាព និងប្រសិទ្ធភាពនៃការអនុវត្តគម្រោងផែនការសកម្មភាព គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សម្របសម្រួល និងជម្រុញកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- ធ្វើកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកជំនួយ សម្រាប់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ឃ- ការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល** មានភារកិច្ច :

- គ្រប់គ្រងឯកសារ ក្របខ័ណ្ឌ និងរៀបចំប្រវត្តិរូបរបស់មន្ត្រីរាជការ
- រៀបចំឯកសារចាត់តាំង និងតែងតាំងមន្ត្រីរាជការក្នុង អ.ទ.ស
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាព និងសមត្ថភាពការងាររបស់មន្ត្រីរាជការ
- រៀបចំផែនការ និងកម្មវិធីបណ្តុះបណ្តាលសម្រាប់អភិវឌ្ឍន៍ធនធានមនុស្សក្នុង អ.ទ.ស
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ប្រការ ៣.-**

នាយកដ្ឋានធនធានធម្មជាតិ មានរចនាសម្ព័ន្ធដូចខាងក្រោម :

ក-ការិយាល័យធនធានទឹក

ខ-ការិយាល័យធនធានរ៉ែ

គ-ការិយាល័យជីវចម្រុះ

ឃ-ការិយាល័យកសិកម្មចម្រុះ

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

៣

**ក- ការិយាល័យធនធានទឹក** មានភារកិច្ច :

- សិក្សាស្រាវជ្រាវអំពីសក្តានុពលធនធានទឹកក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុ ព្រមទាំងកត្តាផ្សេងៗទៀត ដែលនាំឱ្យប៉ះពាល់ដល់ធនធានធម្ម-ជាតិ ក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សា និងកំណត់តំបន់អភិរក្ស និងអភិវឌ្ឍធនធានទឹក
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការប្រើប្រាស់ធនធានទឹក ដើម្បីបង្កើតឡើងនូវវិធានការ បទដ្ឋាន និង អនុសាសន៍ផ្សេងៗ
- លើកគម្រោងរាល់ការស្នើសុំ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានទឹក
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស។

**ខ- ការិយាល័យធនធានរ៉ែ** មានភារកិច្ច :

- សិក្សាស្រាវជ្រាវអំពីសក្តានុពលធនធានរ៉ែក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- លើកគម្រោងរាល់ការស្នើសុំ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានរ៉ែ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពរុករករ៉ែគ្រប់ប្រភេទ ដើម្បីបង្កើតឡើងនូវវិធានការ បទដ្ឋាន និង អនុសាសន៍ផ្សេងៗ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស។

**គ- ការិយាល័យជីវចម្រុះ** មានភារកិច្ច :

- សិក្សាស្រាវជ្រាវអំពីធនធានមច្ឆជាតិ ធនធានព្រៃលិចទឹក និងធនធានជីវចម្រុះផ្សេងៗទៀត ដើម្បីបង្កើតឡើងនូវផែនការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព
- សិក្សាស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុ ដែលធ្វើឱ្យប៉ះពាល់ដល់ជីវចម្រុះ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការប្រែប្រួលធនធានមច្ឆជាតិ និងព្រៃលិចទឹក ដែលបណ្តាលមកពីកត្តាធម្មជាតិ និងកត្តាមនុស្ស ដើម្បីបង្កើតឡើងនូវវិធានការ បទដ្ឋាន និងអនុសាសន៍ផ្សេងៗ
- លើកគម្រោងរាល់ការស្នើសុំ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងជីវចម្រុះ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស។

**ឃ- ការិយាល័យកសិកម្មចម្រុះ** មានភារកិច្ច :

- សិក្សាស្រាវជ្រាវអំពីសក្តានុពលទឹក-ដី សម្រាប់បម្រើឱ្យវិស័យកសិកម្ម
- ប្រមូល និងរៀបចំព័ត៌មានស្តីពីការប្រើប្រាស់ដី
- កំណត់តំបន់អភិវឌ្ឍវិស័យកសិកម្ម
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការប្រើប្រាស់ទឹក-ដី កសិកម្ម ដើម្បីបង្កើតឡើងនូវវិធានការ បទដ្ឋាន និងអនុសាសន៍ផ្សេងៗ
- លើកគម្រោងរាល់ការស្នើសុំ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងកសិកម្មចម្រុះ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស។

**ប្រការ ៤.-**

នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស មានរចនាសម្ព័ន្ធ ដូចខាងក្រោម :

ក-ការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ

ខ-ការិយាល័យអភិរក្ស

គ-ការិយាល័យព័ត៌មានភូមិសាស្ត្រ និងផែនទី

ការិយាល័យនីមួយៗដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**ក- ការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ** មានភារកិច្ច :

- សិក្សា ប្រមូល ចងក្រងព័ត៌មានពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម លើរាល់ធនធានធម្មជាតិក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការធ្វើអាជីវកម្មធនធានទឹក ដី មច្ឆជាតិ រ៉ែ និងជីវចម្រុះផ្សេងៗទៀត ដើម្បីបង្កើតឡើងនូវវិធានការ បទដ្ឋាន និងអនុសាសន៍ផ្សេងៗ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស។

**ខ- ការិយាល័យអភិរក្ស** មានភារកិច្ច :

- ប្រមូល រៀបចំ និងចងក្រងទិន្នន័យជាប្រចាំ នូវព័ត៌មានពាក់ព័ន្ធនឹងតំបន់អភិរក្ស និងតំបន់ការពារក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- កំណត់តំបន់អភិរក្សធនធានទឹក ព្រៃលិចទឹក មច្ឆជាតិ រ៉ែ និងធនធានជីវចម្រុះផ្សេងៗទៀត
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស។

៥

**គ- ការិយាល័យព័ត៌មានភូមិសាស្ត្រ និងផែនទី** មានភារកិច្ច ៖

- ប្រមូល រៀបចំ និងចងក្រងទិន្នន័យជាប្រចាំ នូវព័ត៌មានភូមិសាស្ត្រ ដើម្បីបញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំផែនទីសម្រាប់បម្រើដល់ការងារសម្របសម្រួលការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ប្រការ ៥.-**

នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ មានរចនាសម្ព័ន្ធ ដូចខាងក្រោម ៖

ក-ការិយាល័យនីតិកម្ម

ខ-ការិយាល័យសម្របសម្រួលវិវាទ

គ-ការិយាល័យផ្សព្វផ្សាយព័ត៌មាន

ការិយាល័យនីមួយៗដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**ក-ការិយាល័យនីតិកម្ម** មានភារកិច្ច ៖

- ប្រមូលចងក្រង ឯកសារ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ
- សិក្សា និងរៀបចំលិខិតបទដ្ឋានគតិយុត្តិចាំបាច់សម្រាប់ដំណើរការការងាររបស់ អ.ទ.ស
- ចូលរួមផ្តល់មតិយោបល់លើការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ
- រៀបចំពិធីសារ អនុស្សារណៈ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិនានា
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ខ-ការិយាល័យសម្របសម្រួលវិវាទ** មានភារកិច្ច ៖

- ប្រមូលនិងចងក្រង គម្រោងអភិវឌ្ឍន៍នានាដែលបានបញ្ចប់ និងកំពុងដំណើរការ ព្រមទាំងគម្រោងចប់កិច្ចសន្យា ក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ទទួលពាក្យបណ្តឹង និងសម្របសម្រួលនូវរាល់វិវាទដែលកើតមានឡើងក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**គ-ការិយាល័យផ្សព្វផ្សាយព័ត៌មាន** មានភារកិច្ច :

- ប្រមូលចងក្រង និងរៀបចំព័ត៌មាន ទិន្នន័យ ដែលពាក់ព័ន្ធដល់កិច្ចការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ ក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ផ្សព្វផ្សាយព័ត៌មានបម្រើដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ឱ្យមានប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព
- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល ពាក់ព័ន្ធនឹងការគ្រប់គ្រងអភិរក្ស និងអភិវឌ្ឍន៍ក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ប្រការ ៦.-**

គ្រប់ការិយាល័យចំណុះនាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ត្រូវអនុវត្តនីការងារតាមភារកិច្ច ដែលបានកំណត់ និងតាមឋានានុក្រម ស្របតាមគោលការណ៍រដ្ឋបាលសាធារណៈ ។

**ប្រការ ៧.-**

អនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង ថ្នាក់ដឹកនាំប្រធាននាយកដ្ឋាន និងការិយាល័យនៃអាជ្ញាធរទន្លេសាប ត្រូវអនុវត្តនីប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រធានអាជ្ញាធរទន្លេសាប**

**លឹម គានហោ**

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័ន ជាសមាជិករបស់ អ.ទ.ស
- គ្រប់សាលារាជធានី -ខេត្ត ក្នុងតំបន់ទន្លេសាប

  " ដើម្បីជូនជ្រាប "
- ដូចក្នុងប្រការ ៧ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

៧

## ឧបសម្ព័ន្ធ៥ អនុក្រឹត្យលេខ ១៩៧ អនក្រ.បក ស្តីពីការកំណត់ដែនព្រៃលិចទឹក ចំនួន ៦៤៧.៤០៦ ស្ថិតក្នុងខេត្តតាំង ៦ ជុំវិញបឹងទន្លេសាប

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៩៧ អនក្រ.បក

អាជ្ញាធរទន្លេសាប
ចូល
ថ្ងៃទី 02 ខែ កញ្ញា ឆ្នាំ 2011
ម៉ោង 04 : ... នាទី
លេខ: 133 ...

**អនុក្រឹត្យ**

**ស្តីពី**

**ការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧.៤០៦ ហិកតា ស្ថិតនៅក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប**

**( ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ )**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងបំបនីយជីវមណ្ឌលបឹងទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពី ការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១០ ស្តីពី ការកែសម្រួលមាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពី ការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានកំណត់ដែនព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងកំពង់ធំ ដែលមានផ្ទៃសរុបចំនួន ៦៤៧.៤០៦ ហិកតា រួមមាន ៨០២ ចំណុច ដូចមានក្នុងឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យនេះ ។

**មាត្រា ២ :** ផែនទីបង្ហាញទីតាំងដែនព្រៃលិចទឹក (ដោយមានភ្ជាប់ជូនទាំងនិយាមកា) ក្នុងខេត្តទាំងប្រាំមួយខាងលើ ជាឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៣ :** អំពីភារកិច្ច កាតព្វកិច្ច និងការទទួលខុសត្រូវ លើការគ្រប់គ្រង ការការពារ និងការថែរក្សាដែនព្រៃលិចទឹក និងព្រៃលិចទឹក :

- អភិបាល នៃគណៈអភិបាលខេត្តទាំងប្រាំមួយជុំវិញបឹងទន្លេសាប រួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ មានភារកិច្ច កាតព្វកិច្ច និងការទទួលខុសត្រូវ លើការគ្រប់គ្រង ការការពារ និងការថែរក្សាដែនព្រៃលិចទឹក និងព្រៃលិចទឹក ដូចខាងក្រោម :
  - ១- មានភារកិច្ចគ្រប់គ្រងដោយផ្ទាល់ លើដែនព្រៃលិចទឹកដែលមាននៅក្នុងខេត្តនីមួយៗ
  - ២- មានកាតព្វកិច្ចការពារឱ្យខាងតែបាននូវដែនព្រៃលិចទឹក និងព្រៃលិចទឹកដែលមាននៅក្នុងខេត្តនីមួយៗ
  - ៣- ការបាត់បង់ដែនព្រៃលិចទឹក និងព្រៃលិចទឹក ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចនៃខេត្តណា គណៈអភិបាលនៃខេត្តនោះ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខរាជរដ្ឋាភិបាល ។
- រដ្ឋបាលជលផល ត្រូវធ្វើការត្រួតពិនិត្យជាប្រចាំលើសកម្មភាពថែរក្សា ការពារដែនព្រៃលិចទឹក និងព្រៃលិចទឹករបស់អាជ្ញាធរខេត្តទាំង ០៦ ខាងលើ និងត្រូវចាត់វិធានការតាមច្បាប់ជាបន្ទាន់ ក្នុងករណីពិនិត្យឃើញថា មានសកម្មភាពដែលនាំឱ្យប៉ះពាល់ដល់ដែនព្រៃលិចទឹក និងព្រៃលិចទឹក ។
- អាជ្ញាធរទន្លេសាបមានភារកិច្ចធ្វើអធិការកិច្ចលើគ្រប់សកម្មភាពពាក់ព័ន្ធនឹងដែនព្រៃលិចទឹក និងព្រៃលិចទឹក និងត្រូវធ្វើសេចក្តីរាយការណ៍ពីសកម្មភាពទាំងនោះ ជូននាយករដ្ឋមន្ត្រី ដើម្បីមានវិធានការសម្រេច ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានអាជ្ញាធរទន្លេសាប រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មិថុ ឆ្នាំ ២០១១*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ